# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០១៨

## បុព្វកថា

## រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោក Michael R. Pompeo

សហរដ្ឋអាមេរិក បានយកជាមូលដ្ឋានថា មនុស្សទាំងអស់ ៖ «កើតមកមានភាពស្មើគ្នា ហើយគេកើតមកមានសិទ្ធិខ្លះដែលមិនអាចកាត់ផ្តាច់ចេញបាន ដោយក្នុងចំណោមសិទ្ធិទាំងនេះមានជីវិត សេរីភាព និងសិទ្ធិក្នុងការស្វែងរកសុភមង្គល»។ រដ្ឋធម្មនុញ្ញរបស់យើង ធានាសិទ្ធិដែលគេមិនអាចកាត់ផ្តាច់ចេញបានទាំងនេះ ដោយប្រកាសឲ្យប្រើប្រាស់នូវវិសោធនកម្មទីមួយ ថា «រដ្ឋសភានឹងមិនធ្វើច្បាប់ដែលគោរពដល់ការបង្កើតសាសនា ឬហាមឃាត់ការប្រតិបត្តិសាសនាដោយសេរី ឬបង្រួមសេរីភាពក្នុងការនិយាយស្តី សេរីភាពសារព័ត៌មាន ឬសេរីភាពរបស់ប្រជាជនក្នុងការធ្វើការជួបប្រជុំគ្នា និងសេរីភាពក្នុងការសុំឲ្យរដ្ឋាភិបាលគិតគូរដោះស្រាយរឿងកើតទុក្ខមិនសុខចិត្តណាមួយ»។ វិសោធនកម្មទី ៥ ក៏ចែងផងដែរថា «គេមិនអាចដកហូតចេញពីមនុស្សម្នាក់ នូវជីវិត សេរីភាព ឬទ្រព្យសម្បត្តិ ដោយមិនឆ្លងដំណើរការក្តីត្រឹមត្រូវទេ»។ ទស្សនៈដូចគ្នាទាំងនេះត្រូវបានអនុម័តជាអន្តរជាតិ នៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ពិសេសមាត្រាទី ៣ ១០ ១២ ១៨ ១៩ និង ២០។

អ្នកបង្កបង្កើតសហរដ្ឋអាមេរិក និងប្រតិភូនៅក្នុងគណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ទទួលស្គាល់ថា មនុស្សគ្រប់គ្នាត្រូវតែមានសេរីភាពជាមូលដ្ឋានទាំងនេះ ទាក់ទងនឹងសាសនា ឬជំនឿ ការបញ្ចេញមតិ ការជួបជុំគ្នាដោយសន្តិភាព និងការចងក្រងគ្នាជាក្រុម ជាសមាគម។ សេរីភាពទាំងនេះមិនមែនផ្តល់ឲ្យដោយរដ្ឋាភិបាលទេ តែវាចេញមកពីភាពថ្លៃថ្នូរពីកំណើតរបស់មនុស្ស ហើយវាក៏មិនអាចត្រូវបានរឹតត្បិតដោយមិនសមហេតុផល ដោយរដ្ឋាភិបាលទេ បើទោះបីជាដើម្បីជំរុញបំណងផ្នែកសេដ្ឋកិច្ច សង្គម ឬវប្បធម៌ក៏ដោយ។ គេមិនអាចកាត់ផ្តាច់ចេញបាននូវសេរីភាពទាំងនេះបានទេ។ រដ្ឋាភិបាលមាននាទីក្នុងការធានាថា រដ្ឋាភិបាលខ្លួនឯងមិនជ្រៀតជ្រែកដោយខុស លើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទេ។

បណ្តារដ្ឋអធិបតេយ្យដែលយើងមានកិច្ចសហការយ៉ាងជិតស្និទ្ធ យូរអង្វែង និងប្រកបដោយផ្លែផ្កា គឺជារដ្ឋដែលនៅក្នុងនោះ រដ្ឋាភិបាល ជាទូទៅ គោរពសិទ្ធិមនុស្ស ដែលរួមមានសេរីភាពសាសនា ឬជំនឿ សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបជុំគ្នាដោយសន្តិវិធី និងសេរីភាពក្នុងការចងក្រងជាក្រុម ជាសមាគម ហើយមិនធ្វើការរំលោភលើសិទ្ធិមនុស្សទាំងកំរោល ដូចជាការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការធ្វើទារុណកម្ម ការឃុំខ្លួនយូរតាមទំនើងចិត្ត។ ផ្ទុយទៅវិញ រដ្ឋដែលគំរាមកំហែងសន្តិសុខតំបន់ គឺជារដ្ឋដែលឧបត្ថម្ភដល់ភេរវកម្ម ឬងាយនឹងក្លាយជាគោលដៅនៃការជ្រើសរើសភេរវករ។ រដ្ឋបែបនេះច្រើនតែជារដ្ឋដែលមានរដ្ឋាភិបាលមិនគោរពសិទ្ធិដែលគេមិនអាចកាត់ផ្តាច់ចេញបាន របស់មនុស្សដែលរស់នៅក្នុងរង្វង់ព្រំដែនរបស់ខ្លួន។

គោលនយោបាយរបស់រដ្ឋបាលលោកប្រធានាធិបតី Trump គឺធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាលដទៃទៀត ដោយមិនគិតពីប្រវត្តិរបស់រដ្ឋាភិបាលទាំងនោះទេ បើសិនជាការធ្វើដូច្នេះនឹងជំរុញដល់ផលប្រយោជន៍របស់សហរដ្ឋអាមេរិក។ តែ យើងបានមើលឃើញថា ផលប្រយោជន៍របស់សហរដ្ឋអាមេរិកនៅក្នុងស្ថិរភាព វិបុលភាព និងសន្តិសុខយូរអង្វែងនៃពិភពលោក ដែលពោរពេញទៅដោយរដ្ឋអធិបតេយ្យរឹងមាំ នឹងត្រូវបានធានា បើសិនជារដ្ឋាភិបាលទាំងនោះគោរពសេរីភាពជាមូលដ្ឋាន និងសិទ្ធិមនុស្ស។ ដើម្បីបំណងនេះ សហរដ្ឋអាមេរិកគឺជាមិត្តប្រកបដោយសមានចិត្ត និងជាអ្នកគាំទ្រយ៉ាងរឹងមាំ ចំពោះអ្នកទាំងឡាយណាដែលធ្វើកំណែទម្រង់ដើម្បីបញ្ចប់ការជ្រៀតជ្រែកដោយខុស នៅក្នុងការអនុវត្តសិទ្ធិដែលមិនអាចកាត់ផ្តាច់ចេញបាន មិនថាអ្នកទាំងនោះស្ថិតនៅក្នុងឬនៅខាងក្រៅ រដ្ឋាភិបាលទេ។

របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិមនុស្សនៅតាមប្រទេសមួយៗគឺជាការរួមចំណែកមួយដល់ដំណើរការនេះ។

# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០១៨

## សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា ។ គណបក្សប្រជាជនកម្ពុជា (CPP) បានទទួលបានអាសនៈសភាទាំងអស់ នៅក្នុងការបោះឆ្នោតជាតិ កាលពីថ្ងៃទី ២៩ ខែកក្កដា ដោយបានហាមប្រាមគណបក្សប្រឆាំងធំជាងគេ កាលពីខែវិច្ឆិកា ឆ្នាំ ២០១៧។ នៅមុនពេលទួលជ័យជម្នះនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកាន់តំណែងនេះអស់រយៈពេល ៣៣ ឆ្នាំមកហើយ។ អ្នកសង្កេតការណ៍អន្តរជាតិ ដោយរួមទាំងរដ្ឋាភិបាលបរទេស និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងជាតិ បានរិះគន់ការបោះឆ្នោតនេះ ថាគ្មានភាពសេរី និងយុត្តិធម៌ ហើយមិនតំណាងអោយឆន្ទៈរបស់ប្រជាជនកម្ពុជាទេ។

អាជ្ញាធរស៊ីវិលគ្រប់គ្រងលើកងកម្លាំងសន្តិសុខ ដែលជាញឹកញាប់ គំរាមប្រើកម្លាំង ប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយជាទូទៅ ត្រូវបានគេមើលឃើញថា ជាក្រុមប្រដាប់អាវុធរបស់គណបក្សគ្រប់គ្រងប្រទេស CPP ។

បញ្ហាផ្នែកសិទ្ធិមនុស្សរួមមានការសម្លាប់ដោយខុសច្បាប់ ឬតាមអំពើចិត្ត ដោយរដ្ឋាភិបាល ឬជួសមុខអោយរដ្ឋាភិបាល ការធ្វើអោយបាត់ខ្លួនបង្ខំដោយរដ្ឋាភិបាល ការធ្វើទារុណកម្មដោយរដ្ឋាភិបាល ការចាប់ខ្លួនមនុស្សតាមអំពើចិត្តធ្វើឡើងដោយរដ្ឋាភិបាល អ្នកទោសនយោបាយ ការជ្រៀតជ្រែកតាមអំពើចិត្តនៅក្នុងជីវិតឯកជនរបស់ពលរដ្ឋ ដូចជាការតាមដានជាទូទៅតាមប្រព័ន្ធអេឡិចត្រូនិច ការចាប់ពិរុទ្ធ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការបរិហារកេរ្តិ៍ដោយរើសមុខ ការជ្រៀតជ្រែកនៅក្នុងសិទ្ធិធ្វើការប្រមូលផ្តុំដោយសន្តិភាព និងសេរីភាពក្នុងការចងក្រងគ្នាជាក្រុម សមាគម ការរឹតត្បិតក្នុងការចូលរួមទាក់ទងនឹងនយោបាយ អំពើពុករលួយជាទូទៅ ដោយរួមទាំងនៅក្នុងប្រព័ន្ធតុលាការ និងការបង្ខំអោយកុមារធ្វើពលកម្ម។

រដ្ឋាភិបាលមិនបានផ្តល់ភស្តុតាងនៃការកាត់ទោសមន្ត្រីដែលបានប្រព្រឹត្តបទរំលោភច្បាប់ទេ រួមទាំងអ្នកដែលមានការពាក់ព័ន្ធនឹងករណីពុករលួយ។ វប្បធម៌និទណ្ឌភាពនៅតែមាននៅឡើយ។

## ផ្នែកទី១ ៖ ការគោរពភាពថ្លៃថ្នូររបស់មនុស្ស រួមទាំងសេរីភាពរួចផុតពី ៖

### ក. ការដកហូតជីវិតតាមអំពើចិត្ត និងការសម្លាប់ដោយសារហេតុផលនយោបាយ ឬដោយខុសច្បាប់

មានគេនិយាយថា រដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលបានធ្វើការសម្លាប់មនុស្សតាមអំពើចិត្ត ឬដោយខុសច្បាប់។ គិតមកត្រឹមខែកក្កដា អង្គការ NGO មួយដែលធ្វើការផ្នែកសិទ្ធិមនុស្ស បានរាយការណ៍ពីករណីសម្លាប់ក្រៅប្រព័ន្ធតុលាការចំនួន ៤ ករណី ។

នៅខែមិនា ឆ្នាំ ២០១៧ តុលាការបានកាត់ទោសអោយឈ្មោះ អឿត អាង ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការសម្លាប់លោកកែម ឡី ដែលជាអ្នកវិភាគនយោបាយ ដ៏ក្លាហាន និងប្រកបដោយប្រជាប្រិយភាព កាលពីឆ្នាំ ២០១៦ ។ គិតមកត្រឹមខែកក្កដា ករណីនេះនៅតែបើកចំហនៅឡើយ ហើយរដ្ឋាភិបាលបានសន្យារកមើលអ្នកសមគំនិត តែមិនឃើញមានធ្វើសកម្មភាពអ្វីទេ ។ ដោយកត់សម្គាល់ឃើញ

ថា ជនរងគ្រោះ និងឃាតកមិនបានស្គាល់គ្នា និងលក្ខណៈមិនប្រក្រតីដទៃទៀត ដូចជាការដែលបុរសក្រីក្រូបនេះមានកាំភ្លើងថ្លៃប្រើ អ្នកសង្កេតការណ៍ជាច្រើនជឿថា ភាគីទី ៣ បានជួលឈ្មោះ អឿត អាង។

នៅថ្ងៃទី ៨ មិនា ហិង្សាបានកើតឡើងនៅខេត្តក្រចេះ នៅពេលកម្លាំងសន្តិសុខបាញ់ប្រហារទៅលើអ្នកតវ៉ាការផ្ទេរដីធ្លី កាលពីរាប់ទសវត្សរ៍មុន ទៅឲ្យក្រុមហ៊ុនចំការកៅស៊ូមួយ ។ ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនបានរាយការណ៍ពីការស្លាប់មនុស្សពី ២ ទៅ ៦ នាក់ ហើយ ៤០ នាក់ទៀតបានរងរបួស ។ ក្រោយមានហិង្សានេះបន្តិច រដ្ឋាភិបាលបានបញ្ជារអោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក "កែតម្រូវ" ព័ត៌មានរបស់ខ្លួន។ អង្គការ NGO ចំនួន ៤ និងការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានបង្កើតគណៈកម្មាធិការស៊ើបអង្កេតមួយសម្រាប់ទៅមើលកន្លែងនោះ។ គេបានឃើញថា នៅថ្ងៃទី ៧ មិនា ក្រុមហ៊ុនបានចាប់ផ្តើមព័ទ្ធបងដីរបស់ខ្លួន ហើយមួយថ្ងៃក្រោយមក ទាហាន កងរាជអាវុធហត្ថ និងនគរបាលចំនួន ១៥០ នាក់បានដុតផ្ទះរបស់ប្រជាជននៅក្នុងភូមិ ដែលជាការធ្វើអោយអ្នកភូមិបិទផ្លូវធំ ហើយទាមទារអោយបញ្ឈប់ការដុតផ្ទះទាំងនោះភ្លាម។ បើយោងតាមរបាយការណ៍របស់ស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កម្លាំងសន្តិសុខបានបាញ់បំបែកហ្វូងអ្នកភូមិ។ ស្នងការសិទ្ធិមនុស្សសហប្រជាជាតិបានទទួលស្គាល់ថា ដោយសារកម្លាំងសន្តិសុខបិទមិនឲ្យចូលដល់កន្លែងបាញ់នោះ គេមិនដឹងច្បាស់ពីចំនួនអ្នកស្លាប់ និងរបួសទេ។

បន្ទាប់ពីមានហេតុការណ៍នេះកើតឡើង លោក ស ចំរ៉ុង អភិបាលខេត្តក្រចេះ បានបដិសេធរបាយការណ៍ថា កំលាំងសន្តិសុខបានបាញ់អ្នកតវ៉ា។ លោក គៀត ច័ន្ទថារិទ្ធ អ្នកនាំពាក្យនគរបាលជាតិអះអាងថា អ្នកភូមិ ដោយមានកាំភ្លើងកែច្នៃ បានធ្វើអោយនគរបាលចំនួន ៧ នាក់របួស ចំណែកអ្នកភូមិតែ ២ នាក់ទេ ដែលរងរបួសស្រាល មិនមែនដោយសារគ្រាប់កាំភ្លើងទេ គឺដោយសារចម្រូងឬស្សី។

**ខ. ការបាត់ខ្លួន**

ព្រះតេជគុណ មាស វិចិត្រ ដែលជាសង្ឃមានឈ្មោះល្បីម្នាក់ និងជាសកម្មជនផ្នែកសង្គម ដែលបានបាត់ខ្លួនកាលពីខែមិថុនា ឆ្នាំ ២០១៧ នៅឃុំក្របីរៀល ខេត្តសៀមរាប បន្ទាប់ពីកម្លាំងសន្តិសុខវាយព្រះអង្គ នៅតែបាត់ខ្លួននៅឡើយ ហើយគិតមកដល់ខែតុលា នៅតែគ្មានព័ត៌មានថ្មីទាក់ទងនឹងព្រះអង្គទេ។

គ. ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មបន្ទាបបន្ថោក អមនុស្សធម៌ ឬឃោរឃៅដទៃទៀត

រដ្ឋធម្មនុញ្ញហាមប្រាមទង្វើបែបនេះ តែការវាយដំ និងទម្រង់ដទៃទៀតនៃការធ្វើបាបលើរូបរាងកាយទៅលើអ្នកជាប់ឃុំរបស់នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត នៅក្នុងឆ្នាំនៃរបាយការណ៍។

មានរបាយការណ៍ដែលអាចទុកចិត្តបានថា យោធា និងនគរបាលស៊ីវិលបានធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះ វាយដំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួនដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ គិតមកដល់ខែកក្កដា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ បានសង្កេតឃើញមានធ្វើទារុណកម្មទៅលើអ្នកជាប់ពន្ធនាគារឬអ្នកជាប់ឃុំចំនួន ៩ ករណី ។ លោក គឹម សុខ បានប្រាប់អ្នកសារព័ត៌មានក្នុងស្រុក បន្ទាប់ពីការដោះលែងលោកពីការឃុំឃាំងថា ឆ្មាំគុកបានវាយគាត់ រាល់ពេលលោកមិនព្រមធ្វើតាមបញ្ជា ឬបើកសៀវភៅ។ អ្នកជាប់ឃុំដទៃទៀតបាននិយាយថា អាជ្ញាធរបានបង្ខំអោយពួកគេដើរមួយម៉ោង ដោយទូលទឹកមួយធុង ឬបង្ខំអោយពួកគេឈររាប់ម៉ោងនៅកណ្តាលថ្ងៃ។

គិតមកត្រឹមខែកក្កដា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ បានរាយការណ៍ពីករណីអាជ្ញាធរមូលដ្ឋាន ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សរបស់អ្នកធំវាយដំជនស៊ីវិលដែលមិនជាប់ឃុំចំនួន ៩ ករណី។

## ស្ថានភាពពន្ធនាគារ និងមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមានសភាពយ៉ាប់ខ្លាំង ហើយក្នុងករណីជាច្រើន គំរាមកំហែងដល់អាយុជីវិតទៀតផង ។ កាលពីខែកុម្ភៈ អង្គការពលកម្មអន្តរជាតិ (ILO) បានស្នើសុំអោយរដ្ឋាភិបាលនិយាយការពារការអនុវត្តរបស់ខ្លួនលើពលកម្មដោយបង្ខំសម្រាប់អ្នកជាប់ឃុំ ហើយសុំឲ្យរដ្ឋាភិបាលកែប្រែច្បាប់មួយចំនួន ដើម្បីធ្វើយ៉ាងណាឲ្យការចាប់ឃុំខ្លួនជៀសផុតពីការបង្ខំធ្វើពលកម្ម។

<u>*ទិដ្ឋភាពទីកន្លែង៖*</u> ការមានអ្នកទោសច្រើននាំអោយចង្អៀតខ្លាំងគឺជាបញ្ហាមួយ។ យោងតាមអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ នៅខែកក្កដា ឆ្នាំ ២០១៧ មានអ្នកទោស និងអ្នកជាប់ពន្ធនាគារចំនួនប្រមាណជាង ២៦ ០០០ នាក់ នៅក្នុងពន្ធនាគារចំនួន ២៩ ដែលត្រូវបានបង្កើតឡើងសម្រាប់ដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រឹមតែចំនួន ១១ ០០០ នាក់ប៉ុណ្ណោះ ។ មន្ត្រីផ្នែកពន្ធនាគារបាននិយាយថា «សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន« របស់រដ្ឋាភិបាលបានធ្វើឲ្យពន្ធនាគារកាន់តែចង្អៀតខ្លាំងឡើង។ អគ្គនាយកដ្ឋានពន្ធនាគារមិនព្រមផ្តល់តួលេខចុងក្រោយទេ។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់ឲ្យនៅដាច់ពីគ្នាទេ រវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ រវាងប្រុស និងស្រី ឬរវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាល ឬសម្រាប់ការឃុំមុនសវនាការទេ។ បើយោងតាមអគ្គនាយកដ្ឋានពន្ធនាគារ នៅឆ្នាំ ២០១៦ ក្នុងចំណោមអ្នកទោស មានប្រហែល ៣៤% មិនទាន់កាត់ក្តី ២៩% បានទទួលការកាត់ក្តីចុងក្រោយ ហើយប្រហែល ៨% នៃអ្នកទោសគឺជាស្ត្រី និង ៤% ជាអនីតិជន។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដដែល បានរាយការណ៍ថា ចំនួនកុមារធំ និងតូចដែលស្ថិតនៅជាមួយម្តាយក្នុងពន្ធនាគារ មានការកើនឡើងច្រើន ចាប់ពីឆ្នាំ ២០១៦ មកដោយសាររដ្ឋាភិបាលបើកយុទ្ធនាការប្រឆាំងគ្រឿងញៀន។ យោងតាមអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ចំនួនកុមារតូចៗនៅក្នុងពន្ធនាគារកើនពី ៣០ នៅឆ្នាំ ២០១៥ ដល់ ១៤៩ នាក់ គិតមកដល់ខែមិនា។

គិតមកដល់ខែតុលា នាយកដ្ឋានពន្ធនាគារមិនបានរាយការណ៍ពីចំនួនអ្នកទោសស្លាប់ ក្នុងពន្ធនាគារទេ។ នៅឆ្នាំ ២០១៦ ដែលតាមកំណត់ត្រាគឺជាឆ្នាំចុងក្រោយបំផុត មានស្លាប់ចំនួន ៧៦ នាក់។ អង្គការក្រៅរដ្ឋាភិបាល បាននិយាយថា នៅក្នុងករណីជាច្រើន របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នកទោស ពេលខ្លះ ត្រូវបានកឹបកេងយកដោយអាជ្ញាធរ ដែលជាការធ្វើឲ្យមានកង្វះអាហារូបត្ថម្ភ និងជំងឺអ្នកទោសមានកាន់តែច្រើន។ អាជ្ញាធរមិនបានផ្តល់តួលេខចុងក្រោយស្តីពីចំនួនពន្ធនាគារដែលក្នុងនោះអ្នកទោសមានទឹកស្អាតប្រើប្រាស់ទេ ថ្វីបើ គិតមកដល់ឆ្នាំ ២០១៦ ពន្ធនាគារចំនួន ១៨ ទេ ក្នុងចំណោមពន្ធនាគារចំនួន ២៩ មានផ្តល់ទឹកស្អាត។ ពន្ធនាគារគ្មានកន្លែងគ្រប់គ្រាន់សំរាប់ជនពិការរាងកាយ និងអ្នកឡប់សតិឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានចោទប្រកាន់ថា អ្នកគ្រប់គ្រងពន្ធនាគារប្រព្រឹត្តមិនស្មើគ្នាលើអ្នកទោស ដូចជាករណីផ្តល់ការអនុញ្ញាតអោយអ្នកចូលសួរសុខទុក្ខ ការប្តូរទៅបន្ទប់ល្អ និងឱកាសចេញពីបន្ទប់ នៅពេលថ្ងៃ សំរាប់អ្នកទោសដែលគ្រួសាររបស់គេមានលុយសូក។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ «គណៈកម្មាធិការគ្រប់គ្រងអ្នកទោសដោយខ្លួនឯង» ដែលជាក្រុមអ្នកទោសដែលត្រូវបានចងក្រង និងដឹកនាំដោយឆ្មាំគុក ពេលខ្លះ ធ្វើការវាយដំលើអ្នកទោសដទៃទៀត។ មានសេចក្តីរាយការណ៍ថា មានការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធនាគារយ៉ាងច្រើន ដែលគេអាចធ្វើទៅបានដោយសូកប៉ាន់មន្ត្រីពន្ធនាគារ។

កម្ពុជាមានមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនរបស់រដ្ឋាភិបាលចំនួន ៧ និងមាន៣ ទៀតជារបស់ឯកជន ។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះគឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌល ដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ ដោយគ្មានឆ្លងកាត់ដំណើរការក្តីត្រឹមត្រូវទេ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំទេ។ អ្នកសង្កេតការណ៍បានកត់សំគាល់ឃើញថាបុគ្គលិកក្នុងមណ្ឌលជាញឹកញាប់ប្រើវិធីបង្ខំ ដើម្បី “គ្រប់គ្រង”ទៅលើអ្នកជាប់ក្នុងនោះ និងអោយហាត់ប្រាណយ៉ាងខ្លាំង ។

រដ្ឋបាលៈ អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ សំរាប់ជនល្មើសអហិង្សា។ អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី ដោយមិនមានការត្រួតពិនិត្យកែប្រែឡើយ។ តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលស៊ើបអង្កេតលើពាក្យបណ្តឹងបែបនេះ ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំង តាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារមិនបញ្ចេញរបាយការណ៍នេះទេ ទោះបីជាអង្គការសង្គមស៊ីវិលបានធ្វើការស្នើសុំជាញឹកញាប់ក្តី។

អ្នកទោស និងអ្នកជាប់ការឃុំឃាំងជាធម្មតា ត្រូវបានអនុញ្ញាតអោយជួបជាមួយអ្នកទៅមើល តែអង្គការសិទ្ធិមនុស្សបានអះអាងថា ពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រីពន្ធនាគារដើម្បីបានសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬត្រូវផ្តល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃទៀត ។ មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។ គង់ រ៉ៃយ៉ា និស្សិតម្នាក់ដែលបានជាប់ពន្ធនាគារមួយឆ្នាំ ដោយសារបង្ហោះហ្វេសប៊ុកដែលប៉ះពាល់នយោបាយ បាននិយាយថា គាត់ត្រូវសូកឆ្មាំគុកប្រហែលមួយដុល្លា រាល់ពេលដែលគាត់បានជួបជាមួយអ្នកនយោបាយ សកម្មជនសិទ្ធិមនុស្ស ដែលជាប់ពន្ធនាគារ។

ការតាមដានដោយឯករាជ្យៈ ដោយមានលក្ខខណ្ឌជាមុន និងការដាក់កំហិត ជាទូទៅ រដ្ឋាភិបាលបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរដែនដីនៅមានកម្រិត ដែលជាការធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំដែលមិនទាន់ទទួលការជំនុំជម្រះក្តី ។ រឿងនេះមានជាពិសេសលើករណីធំៗ ដូចជាការឃុំខ្លួនមេដឹកនាំបក្សប្រឆាំង កឹម សុខា ដែលត្រូវបានគេដោះលែងនៅថ្ងៃទី ១០ ខែកញ្ញា បន្ទាប់ពីឃុំមុនសវនាការ នៅក្នុងពន្ធនាគារចំនួនមួយឆ្នាំ ដោយអាជ្ញាធរបានអនុញ្ញាតអោយតែភរិយា និងមេធាវីតែប៉ុណ្ណោះចូលជួប។ ទោះបីជាគ្រួសារសុំអោយកាកបាទក្រហមអន្តរជាតិអាចចូលជួបក្តី តែលក្ខខណ្ឌដែលនៅក្រោមនោះ រដ្ឋាភិបាលអនុញ្ញាតអោយមានការចូលជួបបែបនេះ ដែលរួមមានការជួបដោយមិនផ្ទាល់ដល់ជនជាប់ឃុំ មិនអាចអោយគ្រួសារទទួលយកបានឡើយ។

ក្រសួងមហាផ្ទៃតម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាត មុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ដោយច្រើនតែតម្រូវអោយសុំពីអង្គភាពច្រើនកន្លែងអាស្រ័យលើករណីមួយៗ ហើយក្នុងករណីខ្លះ រដ្ឋាភិបាលតម្រូវអោយអង្គការមិនមែនរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ជាផ្លូវការ ដោយបញ្ជាក់ពី “តួនាទី” របស់គេ ក្នុងពេលទៅមើលអ្នកទោស។

ថ្វីបើក្រុមមនុស្សក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ អាចជួបជាលក្ខណៈឯកជនជាមួយអ្នកទោសក្តី តែអ្នកខ្លះក៏មិនអាចជួបបានទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយដែលជាធម្មតា ផ្តល់ការថែទាំសុខភាពដល់អ្នកទោស បាននិយាយថា ពេលខ្លះ រដ្ឋាភិបាលមិនអនុញ្ញាតអោយគេចូលមើលអ្នកទោសដែលកាត់ក្តីហើយ និងជាសមាជិកនៃគណបក្សប្រឆាំងឡើយ។ អង្គការ NGO មួយទៀតបាននិយាយថា រដ្ឋាភិបាលបានចោទខ្លួនថា មានគំនិតលំអៀងនយោបាយ ហើយប្រើការទៅមើលអ្នកទោសដើម្បីជម្រុញអ្នកទោសនយោបាយឲ្យកាន់តែផ្តើនខ្លាំងឡើង។ តំណាងនៃការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិយាយថា ធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសអ្នកជាប់ពន្ធនាគារពិសេសណាម្នាក់។

## ឃ. ការចាប់ ឬឃុំខ្លួនតាមអំពើចិត្ត

ច្បាប់ហាមប្រាមការចាប់ឬឃុំខ្លួនតាមអំពើចិត្ត តែពេលខ្លះ រដ្ឋាភិបាលមិនបានគោរពបំរាមទាំងនេះទេ ដូចជាបានធ្វើការឃុំខ្លួនតាមអំពើចិត្តលើបុគ្គលិកនៃអង្គការអាដហុកចំនួន ៤២៧ ថ្ងៃ ក្រោមការចោទប្រកាន់ដែលមាន ហេតុផលនយោបាយ។ អាដហុក ស្ថិតក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលចាស់ និងលេចធ្លោជាងគេ នៅកម្ពុជា។ អាជ្ញាធរបានដោះលែងបុគ្គលិកអាដហុកទាំងនោះអោយនៅក្រៅឃុំ នៅខែកក្កដា ឆ្នាំ ២០១៧។ នៅខែកញ្ញា ឆ្នាំ ២០១៨ សវនាការលើករណីរបស់គេត្រូវបានធ្វើឡើងវិញ។

ការប្តឹងផ្តល់ដោយរដ្ឋាភិបាលក្នុងករណីព្រហ្មទណ្ឌទាក់ទងនឹងការបរិហាកេរ្តិ៍ ក៏បាននាំដល់ការចាប់ខ្លួនមួយចំនួនផងដែរ។ ឧទាហរណ៍ មេដឹកនាំកម្មករថ្នាក់ខេត្ត ឈ្មោះ សំ សុខា ត្រូវបានកាត់ទោស និងរកឃើញថា មានទោសកំបាំងមុខ នៅខែមករា ពីបទបរិហារកេរ្តិ៍លើលោក ហ៊ុន សែន បន្ទាប់ពីគាត់បានយកស្បែកជើងវាយរូបលោក ហ៊ុន សែន ហើយត្រូវបានគេថតបាន។ ទោះបីជាឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) បានផ្តល់អោយគាត់នូវឋានៈជាជនភៀសខ្លួននៅប្រទេសថៃក្តី តែរដ្ឋាភិបាលថៃបានចាប់បង្ខំបញ្ជូនគាត់ត្រឡប់មកវិញ តាមសំណើរបស់រដ្ឋាភិបាលកម្ពុជា កាលពីខែកុម្ភៈ ហើយគាត់ត្រូវជាប់ពន្ធនាគារចំនួន ២ ឆ្នាំ។

នៅខែកុម្ភៈ រដ្ឋាភិបាលបានអនុម័តច្បាប់ដាក់ទោសលើអ្នកប្រមាថស្តេច ដែលបាននាំដល់ការចាប់ខ្លួនពលរដ្ឋយ៉ាងហោចណាស់ចំនួន ៣ នាក់។

## តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការដ្ឋាន នគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់ ។ កម្លាំងនគរបាល ត្រូវបែងចែកជាកម្លាំងដែលមានអំណាចដើម្បីធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ដែលអំណាចរបស់ខ្លួនមានដល់ការអនុវត្តដីការបស់តុលាការ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតឲ្យចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំងនោះបំពេញលក្ខខណ្ឌក្នុងការបណ្តុះបណ្តាល និងបទពិសោធន៍ដើម្បីបំពេញការងារជានគរបាលស៊ីវិល ប្រសិនបើជនស៊ីវិលស្ថិតនៅកន្លែងរបស់យោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ តែតាមភាពជាក់ស្តែង កងរាជអាវុធហត្ថធ្វើសកម្មភាពលើជនស៊ីវិលជាធម្មតា ក្រោមការអនុញ្ញាត និងចង្អុលរបស់អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ដោយជាញឹកញាប់ ដើម្បីជួយនគរបាលស៊ីវិលដែលមិនអាចទប់ទល់នឹងហ្វូងមនុស្សដោយខ្លួនឯងបាន។

មានការនិយាយមកថា មន្ត្រីនគរបាលបានប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិទណ្ឌភាព(ភាពគ្មានទោស) ហើយក្នុងករណីភាគច្រើន អាជ្ញាធរបានចាត់វិធានការបន្តិចបន្តួច ឬពុំមានចាត់វិធានការអ្វីឡើយ ។ ជាទូទៅ មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសាររបស់គេមិនត្រូវបានកាត់ទោសទេ។

ពីខែមករាដល់ខែកក្កដា អង្គការសិទ្ធិមនុស្សសក្នុងស្រុកមួយបានបានតាមដានករណីនិទណ្ឌភាពចំនួន ៩ ដែលប៉ះពាល់ដល់ជនរងគ្រោះចំនួន ១០ នាក់។ អង្គការនោះបាននិយាយថា ចំនួនករណីបែបនេះអាចមានច្រើនជាងនេះឆ្ងាយ តែជនរងគ្រោះមិនហានដាក់ពាក្យប្តឹង នៅមុនពេលបោះឆ្នោតដែលមានភាពរសើបផ្នែកនយោបាយ។ ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការវាយតម្លៃការសម្លាប់ដោយកម្លាំងសន្តិសុខ ហើយច្បាប់តម្រូវ ឲ្យនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ។ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និង ព្រះរាជអាជ្ញាកម្រធ្វើការស៊ើបអង្កេតដោយឯករាជ្យណាស់។ ចៅក្រមជំនុំជម្រះ ជាធម្មតា ចេញសាលក្រមផ្អែកតាមតែរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីនគរបាល និងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលស្តីពីការការពារ ឬគោរពសិទ្ធិមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ។

**នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តចំពោះអ្នកជាប់ឃុំ**

ច្បាប់តម្រូវឲ្យនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ជាញឹកញាប់អាជ្ញាធរលើកឡើងពីការលើកលែងនេះ នៅពេលចាប់ខ្លួនតស្សរជននយោបាយបក្សប្រឆាំង បើទោះបីជាបទល្មើសដែលគេចោទនោះ បានកើតឡើងរាប់ឆ្នាំមកហើយក្តី។ អ្នករិះគន់បានចោទរដ្ឋាភិបាលពីការធ្វើដូច្នេះ ដើម្បីគេចពីច្បាប់ដែលផ្តល់អោយសមាជិកសភានូវអភ័យឯកសិទ្ធិសភា។ ច្បាប់អនុញ្ញាតអោយនគរបាលឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបអង្កេតក្នុងរយៈពេល ៤៨ ម៉ោង ដោយមិនរាប់បញ្ចូលរយៈពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ឬជនសង្ស័យត្រូវបានដោះលែង ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់ នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ ម៉ោងបន្ថែមដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្តី ជាទម្លាប់ អាជ្ញាធតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុននឹងធ្វើការចោទប្រកាន់ ។

មានវិធីនៃការធានាឲ្យនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយនៅក្រៅឃុំឡើយ ។ ជាធម្មតា សេចក្តីស្នើឲ្យនៅក្រៅឃុំត្រូវបានបដិសេធចំពោះករណីដែលត្រូវបានចាត់ទុកថា បណ្តាលមកពីហេតុផលនយោបាយ។

តាមច្បាប់ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោង មុននឹងអាចមានមេធាវី ប៉ុន្តែអ្នកជាប់ពន្ធនាគារ ជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងអាចជួបមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ ។ រដ្ឋាភិបាលមិនបានផ្តល់មេធាវីសំរាប់ជនជាប់ឃុំដែលក្រីក្រខ្លាំងទេ។

<u>ការចាប់ខ្លួនតាមអំពើចិត្តៈ</u> គិតមកដល់ខែកក្កដា អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ បាននិយាយថាមានករណីចាប់ខ្លួនតាមអំពើចិត្តចំនួនយ៉ាងហោចណាស់ ៦ ករណីថ្មីទៀត។ ចំនួននៃការចាប់ខ្លួននិងឃុំខ្លួនតាមអំពើចិត្តទំនងជាមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះនៅតាមតំបន់ជនបទមិនប្តឹងដោយសារមានការពិបាកធ្វើដំណើរមកការិយាល័យរបស់អង្គការ ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់គេ។ អាជ្ញាធរមិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនគេដោយខុសច្បាប់ទេ។

គិតមកត្រឹមខែកក្កដា អាជ្ញាធរនៅ មជ្ឈមណ្ឌលសង្គមកិច្ច ព្រៃស្ពឺ ដ៏ចង្អៀតណែន បាននិយាយថាមានអ្នកត្រូវបានឃុំចំនួន ៥៨៥ នាក់ បន្ទាប់ពីមានការប្រមូលចាប់ខ្លួនមនុស្សគ្មានផ្ទះសម្បែង អ្នកសុំ

ទាន អ្នកវិកលចរិក និងអ្នករកស៊ីផ្លូវភេទ ក្នុងយុទ្ធនាការចុះបោសសំអាតតាមផ្លូវក្នុងក្រុងភ្នំពេញ នៅឆ្នាំ ២០១៧។ ពីដំបូង អាជ្ញាធរដាក់មនុស្សចំនួន ១៥៦០ នាក់ ដោយរួមទាំងកុមារចំនួន ២៦២ នាក់ផងនៅមជ្ឈមណ្ឌលព្រៃស្តី ដោយគ្មានផ្តល់ការព្យាបាលជំងឺឬស្បៀងអាហារគ្រប់គ្រាន់។ កន្លែងនោះ ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច ល្បីខាងការរំលោភធ្វើបាប ដែលធ្វើឲ្យអ្នកជាប់ឃុំ ២ នាក់ស្លាប់ នៅក្នុងឆ្នាំ ២០១៥។ យោងតាមអាជ្ញាធរព្រៃស្តី អ្នកជាប់ឃុំចំនួន ៥៨៥ នាក់ស្ថិតនៅទីនោះនៅឡើយ បន្ទាប់ពីការធ្វើសមាហរណកម្មក្នុងសហគមន៍វិញនៃអ្នកជាប់ឃុំពីមុនមកចំនួន ១១០០ នាក់។

<u>ការឃុំខ្លួនមុនសវនាការៈ</u> ច្បាប់អនុញ្ញាតអោយមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះបទល្មើសមធ្យម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ ពេលខ្លះ អាជ្ញាធរឃុំមុនសវនាការដោយគ្មានតំណាងផ្នែកច្បាប់ក្តី។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា អាជ្ញាធរឃុំអ្នកដែលត្រូវបានចោទពីបទល្មើសស្រាល មុនសវនាការលើសរយៈពេល ៦ ខែ។

<u>លទ្ធភាពរបស់អ្នកជាប់ឃុំក្នុងការចោទសួរពីភាពស្របច្បាប់នៃការឃុំខ្លួនមុនចូលតុលាការៈ</u> សំណុំរឿងនៅគរមិនទាន់ចាត់ការ និងការពន្យារពេលយូរក្នុងការទទួលបានសាលដីកា ប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើការតតាំងនៅក្នុងតុលាការប្រឆាំងនឹងមូលដ្ឋានច្បាប់ ឬលក្ខណៈធ្វើតែតាមទំនើងចិត្តនៃការឃុំខ្លួនមនុស្ស។

<u>ការលើកលែងទោសៈ</u> តាមធម្មតា រដ្ឋាភិបាលផ្តល់ការលើកលែងទោស ដែលប្រទានដោយព្រះមហាក្សត្រនៅពេលមានបុណ្យជាតិសំខាន់ៗ។ គិតមកត្រឹមខែកញ្ញា រដ្ឋាភិបាលមិនទាន់បានកំណត់ពេលផ្តល់ការលើកលែងទោស សំរាប់បុណ្យជាតិទេ តែរដ្ឋាភិបាលបានផ្តល់ព្រះរាជលើកលែងទោសមួយចំនួនដល់អ្នកទោសនយោបាយ បន្ទាប់ពីការបោះឆ្នោតជាតិ នៅខែកក្កដា។ នៅខែសីហា រដ្ឋាភិបាលបានលើកលែងទោសអោយមេដឹកនាំគណបក្សប្រឆាំងចំនួន ១៤ នាក់ និងសកម្មជនដីធ្លីចំនួន ៤ នាក់។ រដ្ឋាភិបាលបានប្រកាសជាសាធារណៈច្បាស់ និងតាមការចោទប្រកាន់មកថា តាមរយៈការឃាយីលើបុគ្គលម្នាក់ៗថាអ្នកដែលត្រូវបានលើកលែងទោសទាំងអស់នោះអាចប្រឈមនឹងការចាប់ខ្លួនឡើងវិញ បើការធ្វើសកម្មភាពដែលរដ្ឋាភិបាលចាត់ទុកថាមានបញ្ហា។

**ង. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌**

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែ រដ្ឋាភិបាល ជាទូទៅ មិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងការជ្រៀតជ្រែករបស់ផ្នែកនីតិប្រតិបត្តិ ដែលមានអំណាចដំឡើងសក្តិ បណ្តេញចេញ និងដាក់ពិន័យលើចៅក្រមតាមចិត្ត។ មន្ត្រីតុលាការច្រើនតែមានមុខតំណែងក្នុងពេលជាមួយគ្នា នៅក្នុងគណបក្សកាន់អំណាច ហើយអ្នកសង្កេតការណ៍បាននិយាយថា មានតែអ្នកដែលមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជន ឬផ្នែកប្រតិបត្តិទេ ដែលបានទទួលមុខតំណែងក្នុងតុលាការ។ មានអំពើពុករលួយយ៉ាងរាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។ ផ្នែកតុលាការគ្មានប្រសិទ្ធិភាព ហើយមិនអាចធានាដំណើរក្តីដោយយុត្តិធម៌ត្រឹមត្រូវបានទេ។

អ្នកសង្កេតការណ៍និយាយថា សមាគមមេធាវីជាតិលំអៀងយ៉ាងខ្លាំងទៅរកសមាជិកដែលមានខ្សែស្រឡាយជាមួយគណបក្សប្រជាជន នៅក្នុងការជ្រើសរើសសមាជិក។ ចំណែកមេធាវីមកពីគណបក្សប្រឆាំងឬក្រុមផ្សេងមិនសូវមានឱកាសទេ។ ពេលខ្លះ សមាគមជ្រើសយកអ្នកដែលគ្មានសមត្ថភាពដោយសារតែខ្សែស្រឡាយនយោបាយ។ អ្នកវិភាគដោយមិនលំអៀងបានបង្ហាញអោយឃើញថា អ្នកដាក់ពាក្យចូលជាសមាជិកនៅក្នុងសមាគមនេះបានធ្វើការសូកប៉ាន់យ៉ាងច្រើន ដើម្បីបានចូល។ ជាញឹកញាប់លទ្ធផលនៃសវនាការហាក់មានការកំណត់ទុកជាមុនស្រេច។ ឧទាហរណ៍ នាយករដ្ឋមន្ត្រី ហ៊ុន សែនបានប្រកាសនៅមុនសវនាការរបស់តុលាការកំពូលបន្តិច ស្តីពីការរំលាយគណបក្ស CNRP បន្តិចថា លោកមានការទុកចិត្ត "៩៩,៩៩%" ពីសាលដីកាតុលាការនេះ។

បើតាមអង្គការ NGO កង្វះចៅក្រម និងបន្ទប់តុលាការបានពន្យាករណីជាច្រើន។ នៅខែសីហា សមាគមមេធាវីកម្ពុជាបាននិយាយថា មានចៅក្រមតែចំនួន ១៥១ នាក់តែប៉ុណ្ណោះនៅក្នុងប្រទេស។ អង្គការ NGO ក៏ជឿផងដែរថា មន្ត្រីតុលាការច្រើនផ្តោតលើករណីដែលក្នុងនោះ គេបានទទួលលុយ។ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់រួចផុតពីការកាត់ទោស។ អង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា ដូចនៅក្នុងឆ្នាំកន្លងទៅដែរ ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកម្លាំងសន្តិសុខផង តាមធម្មតា បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរ ដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ អាជ្ញាធរត្រូវបានគេដឹងថា បានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកនូវសំណងប៉ះប៉ូវជាលុយកាក់ ជាថ្នូរនឹងការទម្លាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬការមិនបង្ហាញមុខជាសាក្សី។

**នីតិវិធីជំនុំជម្រះក្តី**

ច្បាប់ចែងពីសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងជាសាធារណៈ តែតុលាការកម្រអនុវត្តច្បាប់លើសិទ្ធិនេះណាស់។

តាមច្បាប់ ចុងចោទមានសិទ្ធិត្រូវបានគេសន្មតថា ជាជនស្លូតត្រង់ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ ជារឿយៗចុងចោទត្រូវសូកប៉ាន់ ជាជាងពឹងលើដំណើរការក្តី ។ សវនាការត្រូវបានធ្វើជាសាធារណៈ តែច្រើនតែត្រូវបានពន្យាពេល ដោយសារការិយាធិបតេយ្យក្នុងតុលាការ។ ចុងចោទមានសិទ្ធិបង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយមេធាវី ប្រឈម និងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយ បង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទគ្មានប្រាក់រកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ នៅក្នុងករណីគ្មានមេធាវីការពារចុងចោទក្នុងរឿងព្រហ្មទណ្ឌ តុលាការពន្យាករណីរហូតទាល់តែមេធាវីត្រូវបានរកបាន ហើយករណីបែបនេះច្រើនតែស៊ីពេលរាប់ខែ។ ការជំនុំជម្រះក្តីច្រើនតែធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ហើយការសួរដេញដោលច្រើនដោយភាគីម្ខាងទៅភាគីម្ខាង ជាធម្មតា មិនបានកើតមានឡើយ ។ ច្បាប់ចែងពីសិទ្ធិទាំងនេះសំរាប់ចុងចោទទាំងអស់។

មានការខ្វះមេធាវីច្រើនដែលមានជំនាញត្រឹមត្រូវ ពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលគ្មានធនធានសំរាប់រកមេធាវី បាត់បង់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌។ របាយការណ៍របស់អង្គការ International Commission of Jurists ឲ្យដឹងថា ការត្រូវធ្វើការសូកប៉ាន់ច្រើនដើម្បីបានចូលជាសមាជិកនៃសមាគមមេធាវីធ្វើឲ្យចំនួនមេធាវីតិច ដែលជាការធ្វើអោយមេធាវីបច្ចុប្បន្នមានឱកាសគ្រប់គ្រាន់ក្នុងការទទួលបានលុយ តាមរយៈមធ្យោបាយស្របច្បាប់ ឬមិនស្របច្បាប់។

អង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍ថា ការថ្លែងជាលាយលក្ខណ៍អក្សររបស់សាក្សី និងអ្នករងការចោទប្រកាន់ច្រើនតែត្រូវបានយកធ្វើជាភស្តុតាងតែមួយគត់ នៅក្នុងសវនាការ។ ពេលខ្លះ អាជ្ញាធរបង្ខំអោយសារភាព ដោយការវាយដំ ឬការគំរាមកំហែង ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់មិនត្រូវបានប្រាប់ពីសេចក្តីនៅក្នុងចម្លើយសារភាព ដែលគេត្រូវបានបង្ខំអោយចុះហត្ថលេខាទៅលើនោះទេ។ តុលាការទទួលយកការសារភាពដោយបង្ខំបែបនេះ យកធ្វើជាភស្តុតាង នៅក្នុងសវនាការ ទោះបីជាមានច្បាប់ហាមការធ្វើដូច្នេះក្តី។ បើយោងតាមអង្គការ NGO ផ្នែកសិទ្ធិមនុស្សមួយ ដែលធ្វើការសង្កេតលើសាលាឧទ្ធរណ៍ ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៧ មានសវនាការ ៣៤០ ករណី ដោយមានចុងចោទចំនួន ៥៥៨ នាក់ ដោយក្នុងនោះមានការគំរាមលើចុងចោទចំនួន ២០ នាក់ ហើយចុងចោទចំនួន ៤០ នាក់ត្រូវបានគេធ្វើទារុណកម្មឲ្យឆ្លើយសារភាព។ ដោយសារការពិបាកនៅក្នុងការដឹក

អ្នកទោសពីពន្ធនាគារខេត្តមកសាលាឧទ្ធរណ៍នៅភ្នំពេញ ចុងចោទមានវត្តមានតែនៅក្នុងតិចជាងពាក់កណ្តាលនៃសវនាការឧទ្ធរណ៍តែប៉ុណ្ណោះ ។

**អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ**

គិតត្រឹមថ្ងៃទី ១ ខែសីហា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយបានប៉ាន់ប្រមាណថា អាជ្ញាធរបានឃុំខ្លួនអ្នកទោសនយោបាយចំនួន ២១ នាក់។ នៅខែកញ្ញា បន្ទាប់ពីមានការលើកលែងទោសក្រោយការបោះឆ្នោត និងការអោយដាក់នៅក្រៅឃុំមួយចំនួន NGO ដដែលនេះបានប៉ាន់ប្រមាណថា មានអ្នកទោសនយោបាយចំនួន ៥ នាក់។

ក្នុងចំណាមអ្នកដែលត្រូវបានដោះលែង នៅក្រោយការបោះឆ្នោត មានប្រធានគណបក្ស CNRP គឺលោក កឹម សុខា។ នៅខែកញ្ញា ឆ្នាំ ២០១៧ នគរបាលបានចាប់ខ្លួនគាត់ ដោយចោទពីករណីក្បត់ជាតិ។ មន្រ្តីជាន់ខ្ពស់គណបក្ស CNRP បានលាក់ខ្លួន ហើយភាគច្រើនគេចទៅបរទេស។ ហេតុផលដែលរដ្ឋាភិបាលលើកឡើងប្រឆាំងនឹងលោក កឹម សុខាគឺផ្អែកលើវីដេអូ កាលពី ៤ ឆ្នាំមុន ដែលក្នុងនោះ មេបក្សនេះបានប្រាប់ទស្សនិកជន នៅប្រទេសអូស្រ្តាលី ពីការងាររបស់គណបក្សលោក នៅក្នុងការរៀបចំការងារនៅតាមមូលដ្ឋាន ដោយមានការណែនាំពីអ្នកជំនាញបរទេស។ រដ្ឋាភិបាលបានអះអាងថា ការនិយាយដូច្នេះស្មើនឹងការដែលលោក កឹម សុខា “សារភាព” ថាប្រទេសមួយទៀតបានប្រាប់គាត់ពីរបៀបបង្កើត “បដិវត្តន៍ពណ៌” នៅកម្ពុជា។ ថ្វីបើអាជ្ញាធរបានឃុំខ្លួនគាត់អស់រយៈពេលមួយឆ្នាំក្តី តែមេធាវីរបស់លោក កឹម សុខាបាននិយាយថា គ្មានភាពរីកចម្រើនទេ នៅក្នុងការស៊ើបអង្កេតរបស់រដ្ឋាភិបាល ថ្វីបើតុលាការបានចោទសួរសាក្សីចំនួន ១៣ នាក់ហើយក្តី ដោយរួមទាំងសកម្មជនសិទ្ធិមនុស្ស ហើយពួកគេជាច្រើនបានអះអាងថា គ្មានជាប់ទាក់ទងអ្វីជាមួយលោក កឹម សុខា ទេ។ នៅថ្ងៃទី ១០ ខែកញ្ញា រដ្ឋាភិបាលបានផ្ទេរលោក កឹម សុខា អោយ “ជាប់ឃុំនៅក្នុងផ្ទះ” វិញ ថ្វីបើនៅក្នុងច្បាប់នៃប្រទេសកម្ពុជា គ្មានមូលដ្ឋានច្បាប់សំរាប់ការដាក់ឃុំនៅក្នុងផ្ទះក្តី។ អាជ្ញាធរមិនអោយកឹម សុខាចេញពីរង្វង់ ៣ ប្លុកនៅជុំវិញផ្ទះរបស់គាត់ ហាមគាត់មិនឲ្យជួបជាមួយអតីតមេដឹកនាំ CNRP អ្នកសារព័ត៌មាន បរទេស និងចូលរួមនៅក្នុងសកម្មភាពឬការជួបជុំនយោបាយ។

នៅខែមេសា សាលាឧទ្ធរណ៍បានដម្កល់ទោសរបស់សកម្មជននៃគណបក្ស CNRP ចំនួន ១១ នាក់ពីបទចោទធ្វើការបះបោរ ហើយបានកាត់ទោសអោយពួកគេជាប់ពន្ធនាគារចំនួនពី ៧ ទៅ ២០ ឆ្នាំ។ អាជ្ញាធរបានចោទពួកគេថាបានចូលរួមនៅក្នុងការតវ៉ានៅក្នុងឆ្នាំ ២០១៤ ដែលនាំអោយមានការរងរបួសដល់អ្នកតវ៉ាចំនួន ៦ នាក់ និងឆ្មាំសន្តិសុខខ័ណ្ឌដូនពេញចំនួន ៣៩ នាក់។

នៅខែកញ្ញា លោក ហ៊ុន សែនបានដោះលែងអតីតសមាជិកសភា អ៊ុំ សំអាន រួមជាមួយនឹងមេដឹកនាំគណបក្ស CNRP ចំនួន ១៣ នាក់ទៀត តាមរយៈមហាក្សត្រព្រះរាជទានទោស។ ពួកគេត្រូវបានចាប់ខ្លួនតាំងពីឆ្នាំ ២០១៦ ត្រូវបានចោទប្រកាន់ ដែលមើលទៅមានលក្ខណៈនយោបាយ ហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ៣០ ខែ។

**នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ**

ប្រទេសកម្ពុជាមានប្រព័ន្ធមួយសម្រាប់ដោះស្រាយបណ្តឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយតាមផ្លូវរដ្ឋបាល ទាំងដំណោះស្រាយតាមផ្លូវតុលាការ តែអាជ្ញាធរច្រើនតែមិនអនុវត្តសាលដីកាតុលាការ។

**សំណងទ្រព្យសម្បត្តិ (Property Restitution)**

ការបង្ខំយកមកដាក់ជាសមូហភាព នៅក្រោមរបបខ្មែរក្រហម និងការផ្លាស់ទីលំនៅរបស់ប្រជាជនបានធ្វើឲ្យកម្មសិទ្ធិដីធ្លីមានភាពមិនច្បាស់លាស់។ ច្បាប់ភូមិបាលចែងថា អ្នកដែលមានកម្មសិទ្ធិដោយសុខសាន្តលើដីឯកជន ឬដីរដ្ឋ (មិនរាប់បញ្ចូលដីសាធារណៈ ដូចជាសួនច្បារ) ឬបានរស់នៅក្នុងអាគាររដ្ឋ ដោយគ្មានការតវ៉ាទាមទារពីអ្នកផ្សេង ក្នុងរយៈពេល ៥ឆ្នាំ មុនការប្រកាសឲ្យប្រើច្បាប់នេះ នៅឆ្នាំ ២០០១ មានសិទ្ធិដាក់ពាក្យសុំកម្មសិទ្ធិលើដី/អាគារនោះជាស្ថាពរ។ តែ ប្រជាជនភាគច្រើននៅតែខ្វះការយល់ដឹង និងមធ្យោបាយសំរាប់ទទួលបានឯកសារកម្មសិទ្ធិដីធ្លីជាផ្លូវការគ្រប់គ្រាន់។

ការិយាល័យសុរិយោដីខេត្តនិងស្រុកបន្តធ្វើតាមនិតិវិធីនៃការចុះបញ្ជីដីមុនឆ្នាំ ២០០១ ដែលមិនបញ្ចូលការសិក្សាអង្កេតបានត្រឹមត្រូវលើដី ឬឱកាសសំរាប់ឲ្យសាធារណជនផ្តល់មតិ។ ការទិញដីទុកលក់ដោយគ្មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ បានបណ្តាលអោយមានជម្លោះ នៅគ្រប់ខេត្តទាំងអស់ ហើយបានបង្កើនភាពតានតឹងរវាងអ្នកភូមិក្រីក្រតាមជនបទ និងឈ្មួញទិញលក់ដី។ សហគមន៍រស់នៅតាមតំបន់ក្រុងប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ដើម្បីយកកន្លែងសំរាប់គម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្ម។

អាជ្ញាធរបានបន្តបង្ខំឲ្យអ្នកស្រុកផ្លាស់ទីលំ ទោះបីក្នុងប៉ុន្មានឆ្នាំមកនេះ មានការថយចុះក្តី។ អ្នកខ្លះប្រើការគំរាមកំហែងប្តឹង ឬបណ្តេញចេញ ដើម្បីសម្លុតអ្នកក្រ និងអ្នកស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ ឲ្យទូទាត់សំណងដីរបស់គេ នៅក្នុងតម្លៃក្រោមតម្លៃទីផ្សារ។ ដោយគិតមកត្រឹមខែមិនា អង្គការNGO ក្នុងស្រុកមួយបាននិយាយថា បានពួករណីថ្មីចំនួន ២៧ ទាក់ទងនឹងការចាប់យកដី និងការបណ្តេញចេញ ដែលមានទៅលើគ្រួសារចំនួន ១៦៤៧។ អង្គការ NGO មួយទៀតបានរាយការណ៍ពីជម្លោះថ្មីទាក់ទងនឹងដីធ្លី រវាងអ្នកជំនួញ និងអ្នកភូមិ ដោយមានការចោទប្រកាន់ពីការទន្ទ្រានចាប់យកដី ការលួចធនធានធម្មជាតិ ដីសម្បទានសេដ្ឋកិច្ច និងការបណ្តេញចេញពីដីធ្លី។ អ្នកដែលរងការបណ្តេញចេញខ្លះបានតវ៉ាបានជោគជ័យនៅតុលាការ តែករណីភាគច្រើនមិនទាន់ត្រូវបានគេចាត់ការទៅលើទេ។

### ច. ការជ្រៀតជ្រែកតាមអំពើចិត្តក្នុងភាពឯកជន គ្រួសារ គេហដ្ឋាន ឬក្នុងការឆ្លើយឆ្លងគ្នា

ថ្វីបើច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុសច្បាប់ ក្តី តែអង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជាទម្លាប់ នគរបាលធ្វើការឆែកឆេរ និងរឹបអូស ដោយគ្មានដីកាពីតុលា ។ រដ្ឋាភិបាលបានដាក់កាមេរ៉ាថតនៅកន្លែងគណកម្មាធិការបោះឆ្នោតជាតិ ។ ជាធម្មតា រដ្ឋាភិបាលបញ្ចេញសារឆ្លើយឆ្លងផ្ទាល់ខ្លួន ហើយថតការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទរបស់មេដឹកនាំបក្សប្រឆាំង និងមេដឹកនាំសង្គមស៊ីវិល ហើបញ្ចេញទៅអោយប្រព័ន្ធផ្សព្វផ្សាយដែលត្រូវគ្នាជាមួយរដ្ឋាភិបាល។ នគរបាលដែលចាប់លោក កឹម សុខា នៅខែ កញ្ញា ត្រូវបានគេនិយាយថា បានចូលផ្ទះគាត់ដោយប្រើកម្លាំង ហើយគ្មានដីកាតុលាការទេ។ អាជ្ញាធរមូលដ្ឋានបានចូលនិងឆែកឆេរអង្គការសហគមន៍ និងការិយាល័យសហជីពកាន់តែញឹកញាប់ឡើង។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

### ក. សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

ថ្វីបើរដ្ឋធម្មនុញ្ញមានចែងពីសេរីភាពបញ្ចេញមតិ រួមទាំងសេរីភាពផ្នែកសារព័ត៌មានក្តី តែក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលបានខិតខំច្រើនក្នុងការធ្វើឲ្យផ្នែកសារព័ត៌មានឯករាជ្យចុះខ្សោយ ហើយធ្វើការរឹតត្បិតច្រើនជាងមុនទៅលើសេរីភាពក្នុងការបញ្ចេញមតិ។

<u>សេរីភាពក្នុងការបញ្ចេញមតិៈ</u> រដ្ឋធម្មនុញ្ញអនុញ្ញាតឲ្យមានការបញ្ចេញមតិដោយសេរី លើកលែងតែក្នុងករណីដែលប៉ះពាល់ដល់សន្តិសុខសាធារណៈ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ «មិនអាចត្រូវគេរំលោភបាន» ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មី

នូវដែនកំណត់ទាំងនេះ ហើយហាមប្រាមមិនអោយអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណាដែលប្រមាថ និងបរិហាកេរ្តិ៍ព្រះមហាក្សត្រ ថ្នាក់ដឹកនាំនិងស្ថាប័នរដ្ឋាភិបាល ។

ច្បាប់បោះឆ្នោត តម្រូវឲ្យអង្គការសង្គមស៊ីវិលមានភាព "អព្យាក្រឹត" នៅក្នុងអំឡុងពេលនៃយុទ្ធនាការនយោបាយ ហើយហាមពួកគេមិនឲ្យ "ប្រមាថ" គណបក្សនយោបាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ថ្វីបើច្បាប់ទាក់ទងនឹងយុទ្ធនាការតម្រូវឲ្យអង្គភាពសារព័ត៌មានធ្វើការផ្សាយឲ្យបានស្មើភាពសម្រាប់គណបក្សនិមួយៗដែលចូលរួមក្នុងការបោះឆ្នោតក្តី តែគេគ្មានឃើញមានភស្តុតាងបង្ហាញពីការអនុវត្តច្បាប់នេះឡើយ ហើយអង្គភាពសារព័ត៌មានផ្សាយឲ្យគណបក្សប្រជាជនកម្ពុជាច្រើនជាងគណបក្សដទៃទាំងអស់។

រដ្ឋាភិបាលបានប្រើក្រមព្រហ្មទណ្ឌដើម្បីកាត់ទោសពលរដ្ឋពីបទបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់ ដែលអាចនាំដល់ការដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាអោយបង់ការផាកពិន័យផងដែរ ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។ តុលាការបានបកស្រាយក្នុងលក្ខណៈទូលំទូលាយនូវទោស "ញុះញង់" ហើយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលបានគំរាមតស៊ូរជនគណបក្សប្រឆាំង ពីបទញុះញង់ ដោយសារអំពើ ដូចជាការអំពាវនាវឲ្យមាន "ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល" តាមរយៈការបោះឆ្នោត។

នៅខែកុម្ភៈ រដ្ឋាភិបាលបានកែប្រែច្បាប់ ដោយដាក់ទោសព្រហ្មទណ្ឌចំពោះការប្រមាថស្តេច។ គិតមកត្រឹមខែកញ្ញា រដ្ឋាភិបាលបានចាប់ខ្លួនមនុស្សយ៉ាងតិច ៣ នាក់ពីបទប្រមាថស្តេច។ នៅថ្ងៃទី៤ តុលា តុលាការនៅខេត្តសៀមរាបបានដាក់ទោសអ្នកកាត់សក់ ឈ្មោះ បាន សំភី ដែលជាសមាជិកម្នាក់នៃគណបក្ស CNRP ដែលត្រូវបានរំលាយ អោយជាប់ពន្ធនាគារចំនួន ៧ ខែ បន្ទាប់ពីគាត់បាន Share ខ្លឹមសារក្នុងហ្វេសបុក ស្តីពីព្រះមហាក្សត្រ នរោត្តម សីហមុនី កាលពីខែឧសភា។ នេះគឺជាការដាក់ទោសលើកដំបូងចាប់តាំងពីរដ្ឋាភិបាលអនុម័តច្បាប់ទាក់ទងនឹងការប្រមាថស្តេច។

អង្គការ NGO ក្នុងស្រុកចំនួន ១១៧ បានសំដែងកាលពីខែមិថុនា នូវកង្វល់លើការបង្ក្រាបរបស់រដ្ឋាភិបាល លើសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទាក់ទងនឹងភាពជាឯកជនរបស់គេ ដោយសាររដ្ឋាភិបាលធ្វើការតាមដានលើការហៅទូរស័ព្ទជាឯកជន និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គេ។

<u>សេរីភាពសារព័ត៌មានៈ</u> កាសែតជាភាសាខ្មែរភាគច្រើន ទទួលបានការគាំទ្រថវិកាពីបុគ្គលដែលស្និទ្ធនឹងគណបក្សប្រជាជនដែលកំពុងដឹកនាំប្រទេស ឬមានអ្នកទាំងនោះជាម្ចាស់។ រដ្ឋាភិបាល កងកម្លាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយ ។ ស្ថានីយ៍វិទ្យុ និងស្ថានីយ៍ទូរទស្សន៍ភាគច្រើន ស្ថិតក្រោមការគ្រប់គ្រង ឬក្រោមឥទ្ធិពលយ៉ាងខ្លាំងរបស់គណបក្សប្រជាជនកម្ពុជា ។ កាសែតចំនួន ៣ ដែលបោះពុម្ពច្រើនជាងគេ ហើយគាំទ្រគណបក្សប្រជាជន មិនដែលរិះគន់រដ្ឋាភិបាលពីបញ្ហាសិទ្ធិមនុស្ស ឬបញ្ហាដែលមានលក្ខណៈនយោបាយទេ។ គិតមកត្រឹមខែសីហា គ្មានកាសែតប្រឆាំងចេញទៀងទាត់ទេ ហើយអាជ្ញាធរមិនដែលអនុញ្ញាតអោយគណបក្ស CNRP មានស្ថានីយទូរទស្សន៍ទេ ទោះបីជាកាលពីឆ្នាំ ២០១៤ រដ្ឋាភិបាលបានផ្តល់ការយល់ព្រមក្តី។

កាលពីខែឧសភា គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញក្រមប្រតិបត្តិមួយសំរាប់ការបោះឆ្នោតខែកញ្ញា ដោយប្រាប់អ្នកសារព័ត៌មានថា ពួកគេនឹងប្រឈមការដាក់ពិន័យចំនួនរហូតដល់ ៣០ លានរៀល (៧ ៥០០ ដុល្លា) បើសិនជាគេសម្ភាសអ្នកបោះឆ្នោត នៅជិតស្ថានីយ៍បោះឆ្នោត ឬបើគេបោះពុម្ពផ្សាយព័ត៌មានដែលអាចប៉ះពាល់ដល់ស្ថិរភាពនយោបាយ ឬបណ្តាលអោយសាធារណជនបាត់បង់ទំនុកចិត្តលើការបោះឆ្នោត។ នៅខែឧសភានោះដែរ រដ្ឋាភិបាលរដ្ឋាភិបាលហាក់រៀបចំការលក់កាសែតឯករាជ្យចុងក្រោយគេនៅកម្ពុជា ទៅឲ្យអ្នកជំនួញជាជនជាតិម៉ាឡេស៊ី ដែលផ្សព្វផ្សាយមុខជំនួញរបស់គាត់ថាជា "ទំនាក់ទំនងសាធារណៈជាសម្ងាត់"។

នៅខែកញ្ញា ឆ្នាំ ២០១៧ កាសែត *The Cambodia Daily* ដែលជាកាសែតឯករាជ្យជាភាសាអង់គ្លេសមួយក្នុងចំណោមកាសែតឯករាជ្យជាភាសាអង់គ្លេសចំនួន ២ ត្រូវបានបិទ បន្ទាប់ពីរយៈពេល ២៥ នៃការបោះពុម្ពផ្សាយ។ រដ្ឋាភិបាលបានចោទកាសែតនេះថា បានគេចមិនបង់ពន្ធចំនួន ២៥,២ ពាន់លានរៀល (៦,៣ លានដុល្លា)។ តែផ្នែកពន្ធដាមិនព្រមបង្ហាញព័ត៌មានលម្អិតស្តីពីការចោទប្រកាន់ទេ ហើយព័ត៌មាន

ស្តីពីប្រាក់មិនទាន់បានបង់ពន្ធបានផ្លាយចេញយ៉ាងរហ័សដោយប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយរដ្ឋាភិបាល ទោះបីជាមានការទាមទារដោយច្បាប់ឲ្យរដ្ឋាភិបាលដោះស្រាយករណីមិនបង់ពន្ធជាសម្ងាត់ក្តី។ នៅខែសីហា រដ្ឋាភិបាលបានបិទវិទ្យុ FM ចំនួន ៣២ នៅតាមខេត្តចំនួន ២០ ដែលជាការប៉ះពាល់ដល់ស្ថានីយដែលផ្សាយបន្តនូវព័ត៌មានឯករាជ្យ ពីវិទ្យុអាស៊ីសេរី វិទ្យុវីអូអេ និងវិទ្យុសម្លេងប្រជាធិបតេយ្យ។

<u>អំពើហិង្សា និងការយាយី៖</u> ហិង្សា និងការគំរាមកំហែងលើអ្នកសារព័ត៌មាននៅមានច្រើននៅឡើយ។ បើយោងតាមមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ចំនួន ៣៨% នៃអ្នកសារព័ត៌មានបាននិយាយថា អាជ្ញាធររដ្ឋាភិបាលបានវាយប្រហារជាពាក្យសម្តី ឬលើរាងកាយលើពួកគេ នៅក្នុងឆ្នាំ ២០១៧។

នៅក្នុងការបោះឆ្នោតឃុំ កាលពីខែឧសភា ឆ្នាំ ២០១៧ អាជ្ញាធរបានចោទប្រកាន់អ្នកកាសែត Cambodia Daily ពីរនាក់ពីបទ “ញុះញង់” និងរំលោភលើសិទ្ធិអ្នកបោះឆ្នោត ដោយតាមការចោទប្រកាន់នោះ បានសួរគេអំពីអ្នកដែលគេចង់បោះឆ្នោតឲ្យ ។ អ្នកកាសែតទាំងពីរនាក់នោះបានគេចចេញពីប្រទេស ហើយក្តីក្តាំលើពួកគេបានបន្តដោយកំបាំងមុខ។

អាជ្ញាធរបានដោះលែងអតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី ២ នាក់ ឲ្យនៅក្រៅឃុំ នៅខែកញ្ញា បន្ទាប់ពីការចាប់ខ្លួនពួកគេកាលពីខែវិច្ឆិកា ឆ្នាំ ២០១៧ ពីបទចោទក្បត់ជាតិ ដោយក្រោយមក អាជ្ញាធរបានបន្ថែមបទចោទចែកចាយរូបអាសអាភាស។

<u>ការចាប់ពិរុទ្ធ ឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ៖</u> ច្បាប់ហាមការចាប់ពិរុទ្ធមុនបោះពុម្ពផ្សាយ ហើយគ្មានប្រព័ន្ធចាប់ពិរុទ្ធផ្លូវការទេ។ តែរដ្ឋាភិបាលបានប្រើកាន់តែច្រើនឡើងនូវមធ្យោបាយផ្សេងទៀតដើម្បីធ្វើការចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ក្រៅពីការគំរាមកំហែង ហឹង្សាការយាយយី ការចាប់ខ្លួន និងការសង្កេតតាមដាន រដ្ឋាភិបាលបានប្រើការគ្រប់គ្រងលើច្បាប់អនុញ្ញាតនិងអាជ្ញាបណ្ណសម្រាប់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឬគណបក្ស CPP។ ប្រព័ន្ធផ្សព្វផ្សាយឯកជនបានសារភាពថា បានធ្វើការចាប់ពិរុទ្ធលើខ្លួនឯងខ្លះ ដោយខ្លាចរដ្ឋាភិបាលធ្វើការសងសឹក។ ល។ បើយោងតាម CCIM ចំនួន ៦៧% នៃអ្នកសារព័ត៌មានមានការខ្លាចរអាក្នុងការធ្វើសេចក្តីរាយការណ៍ទាក់ទងនឹងបញ្ហានយោបាយ និងសិទ្ធិមនុស្ស។

<u>ច្បាប់បរិហារកេរ្តិ៍៖</u> រដ្ឋាភិបាលប្រើច្បាប់បរិហារកេរ្តិ៍ មួលបង្កាច់ បកអាក្រាត ដើម្បីធ្វើការរឹតត្បិតលើការពិភាក្សាគ្នាជាសាធារណៈលើបញ្ហាដែលរដ្ឋាភិបាលគិតថាមានភាពរសើប ឬប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។ នៅថ្ងៃទី ១៧ ខែសីហា អាជ្ញាធរបានដោះលែងលោក គឹម សុខ បន្ទាប់ពីគាត់បានអនុវត្តទោសចំនួន ១៨ ខែនៅក្នុងពន្ធនាគារ ក្រោយការប្តឹងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានអះអាងថា លោកគឹម សុខបានចោទគាត់ថា ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់លោកកែម ឡី។ គិតមកដល់ខែកញ្ញា លោក គឹម សុខមិនបានបង់លុយចំនួន ៨០០ លានរៀល (២ សែនដុល្លា) ជាសំណងដល់លោកនាយរដ្ឋមន្ត្រីទេ។ ការខកខានមិនបានបង់នេះអាចនាំឲ្យមានការជាប់ពន្ធនាគារចំនួន ២ ឆ្នាំថែមទៀត។ លោក គឹម សុខថែមទាំងបានប្រឈមនឹងបទចោទប្រកាន់ថា បានបរិហាកេរ្តិ៍គណបក្សប្រជាជន ដែលគាត់បានចោទថា បានជួលឃាតក។

<u>សន្តិសុខជាតិ៖</u> រដ្ឋាភិបាលតែងតែលើកឡើងពីកង្វល់សន្តិសុខជាតិធ្វើជាហេតុផលនៃការរឹតត្បិតលើសិទ្ធិរបស់ពលរដ្ឋ ដែលរិះគន់មន្ត្រី និងនយោបាយរដ្ឋាភិបាល។ ដោយឡែក រដ្ឋាភិបាលតែងតែគំរាមកាត់ទោស និងចាប់ខ្លួនអ្នកដែលចោទសួរពីការកំណត់ព្រំដែនរបស់រដ្ឋាភិបាលជាមួយប្រទេសវៀតណាម ឬអ្នកដែលនិយាយថា រដ្ឋាភិបាលបានកាត់ដីឲ្យវៀតណាម ។

**សេរីភាពអ៊ីនធឺណែត**

រដ្ឋាភិបាលបានដាក់កំហិតនិងបង្អាក់លើការទទួលបានអ៊ិនធឺណែតប្រើ ចាប់ពិរុទ្ធលើខ្លឹមសារបង្ហោះតាមអ៊ិនធឺណែត ហើយមានសេចក្តីរាយការណ៍ដ៏គួរឲ្យទុកចិត្តបានថា ស្ថាប័នរដ្ឋាភិបាលបានតាមដានការទាក់ទងគ្នាជាឯកជន តាមអ៊ិនធឺណែត។ បើយោងតាម សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ចំនួន ៣៤% នៃប្រជាជនកម្ពុជាមានប្រើសេវាអ៊ិនធឺណែត នៅឆ្នាំ២០១៧។

ច្បាប់ស្តីពីទូរគមនាគមន៍ ត្រូវបានគេរិះគន់ជាទូទៅ ដោយសកម្មជនសិទ្ធិមនុស្ស និងសង្គមស៊ីវិលធំៗនៅក្នុងប្រទេស ដែលបានអះអាងថា វាផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចទូលំទូលាយក្នុងការលួចស្តាប់ការពិភាក្សាជាសាធារណៈតាមអ៊ិនធឺណែត ដោយប្រើឧបករណ៍ទាក់ទងគ្នាជាឯកជន។ រដ្ឋាភិបាលមានអំណាចតាមផ្លូវច្បាប់ក្នុងការតាមដានគ្រប់ការសន្ទនាតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីម៉េល សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងការឆ្លើយឆ្លងរបស់បុគ្គល ដោយគ្មានការយល់ព្រមឬដឹងពីពួកគេ។ មតិសំដែង ដែលត្រូវបានគេគិតថា រំលោភលើន័យសន្តិសុខជាតិដែលកំណត់ដោយរដ្ឋាភិបាល អាចនាំដល់ការចាប់ដាក់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ។

នៅខែឧសភា រដ្ឋាភិបាលបានបានចេញបទបញ្ជាអន្តរក្រសួង ដែលមានឈ្មោះថា “ការគ្រប់គ្រងលើការគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម នៅព្រះរាជាណាចក្រកម្ពុជា” ។ បទបញ្ជានេះផ្តល់អោយរដ្ឋាភិបាលនូវអំណាចបិទទំព័រផ្សព្វផ្សាយសង្គម ឬគេហទំព័រ ដែលផ្សព្វផ្សាយព័ត៌មានដែលបំផ្លាញការការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាតិជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សង្គម ការរើសអើង ឬប្រពៃណី ឬវប្បធម៌ជាតិ។ បទបញ្ជានេះត្រូវបានយកមកប្រើជាលើកដំបូង ៣ ថ្ងៃ មុនការបោះឆ្នោតជាតិ ២៩ កក្កដា នៅពេលរដ្ឋាភិបាលបានបញ្ជារអោយក្រុមហ៊ុនទូរគមនាគមន៍ក្នុងស្រុកបិទគេហទំព័រព័ត៌មានឯករាជ្យមួយចំនួន ដែលរួមមានវិទ្យុសម្លេងសហរដ្ឋអាមេរិក វិទ្យុអាស៊ីសេរីជាភាសាខ្មែរ និងវិទ្យុសម្លេងប្រជាធិបតេយ្យ។

“ក្រុមសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណែត” នៅក្នុងអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស របស់ទីស្តីការគណៈរដ្ឋមន្ត្រី មាននាទីតាមដាន និងប្រឆាំងនឹងព័ត៌មាន “មិនត្រឹមត្រូវ” ពីផ្នែកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ អង្គភាពប្រតិកម្មរហ័ស មាននាទីទទួលខុសត្រូវក្នុងការផ្សាយវីដេអូដែលនិយាយថាសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងគណបក្សប្រឆាំងឃុបឃិតជាមួយមហាអំណាចបរទេស ដើម្បីផ្តួលរំលំរដ្ឋាភិបាល។ រដ្ឋាភិបាលច្រើនប្រើវីដេអូទាំងនេះធ្វើជាហេតុផលសម្រាប់បង្ក្រាបទៅលើអ្នកដែលប្រឆាំងនឹងការគ្រប់គ្រងរបស់លោកនាយករដ្ឋមន្ត្រី។ នៅក្នុងយុទ្ធនាការបោះឆ្នោត ឆ្នាំ ២០១៨ លោកនាយករដ្ឋមន្ត្រីតែងតែគំរាមថា អ្នកជំនាញខាងអ៊ិនធឺណែតរបស់លោកអាចរកឃើញទូរស័ព្ទរបស់អ្នកដែលបង្ហោះសារបរិហារកេរ្តិ៍តាមហ្វេសបុក តែក្នុងរយៈពេល ៤ នាទី។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

ជាទូទៅ រដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌នានាឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ ។ មានគ្រូជាច្រើនធ្វើការចាប់ពិរុទ្ធលើខ្លួនឯង ឬសំដែងមតិជាលក្ខណៈមិនបញ្ចេញឈ្មោះ។ នៅខែកក្កដា សកម្មជនសង្គមស៊ីវិលបានរិះគន់រដ្ឋាភិបាលថា ទិញសន្លឹកឆ្នោត នៅពេលក្រសួងអប់រំបញ្ជាឲ្យបិទសាលារៀនចំនួន ៣ ថ្ងៃ ដើម្បីឲ្យសិស្សវិលត្រឡប់ទៅបោះឆ្នោត នៅខេត្តរបស់គេ។ អ្នករិះគន់ចាត់ទុកទង្វើនេះជារឿងធំ នៅក្នុងបរិបទនៃការបោះឆ្នោត ដែលរដ្ឋាភិបាលចង់ធ្វើឲ្យមានអ្នកទៅបោះឆ្នោតឲ្យបានច្រើន ដើម្បីជំរុញភាពស្របច្បាប់នៃការបោះឆ្នោត ពីព្រោះរដ្ឋាភិបាលមិនបានអនុវត្តគោលការណ៍នេះស្មើគ្នា នៅក្នុងវិស័យនោះទេ។ ឧទាហរណ៍ រដ្ឋាភិបាលមិនបានផ្តល់ដល់កម្មកររោងចក្រនូវថ្ងៃសម្រាកពីការងារបន្ថែម ដើម្បីទៅបោះឆ្នោតទេ។

## ខ. សេរីភាពប្រមូលផ្តុំគ្នា និងសេរីភាពបង្កើតអង្គការ/សមាគម

## សេរីភាពប្រមូលផ្តុំគ្នា ដោយសន្តិវិធី

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី ប៉ុន្តែមានពេលខ្លះ រដ្ឋាភិបាលមិនបាន គោរពសិទ្ធិនេះទេ ។

ច្បាប់ស្តីពីអង្គការ សមាគមតម្រូវឲ្យអង្គការ សមាគមទាំងអស់ចុះបញ្ជី ហើយតំរូវឲ្យមានការប្រាប់ ជាមុននូវការប្រជុំ ការបើកវគ្គរៀនសូត្រ ការតវ៉ា ការដើរក្បួន ឬបាតុកម្ម តែអាជ្ញាធរមិនបានអនុវត្ត បានខ្ជាប់ខ្ជួនលើការទាមទារនេះទេ។ ខមួយចែងពីការត្រូវជម្រាបប្រាប់ចំនួន ៥ ថ្ងៃមុន សម្រាប់ការធ្វើ បាតុកម្មដោយសន្តិវិធីភាគច្រើន ចំណែកខមួយទៀតចែងពីការតម្រូវឲ្យជូនដំណឹងចំនួន ១២ ម៉ោងមុន សម្រាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែង ឯកជន ឬសម្រាប់ការតវ៉ានៅ កន្លែងកំណត់ ហើយកម្រិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុង មានអំណាចសម្រេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រី អាជ្ញាធរថ្នាក់ក្រោមបដិសេធសំណើសុំ បើសិនជាថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាស់លាស់សម្រាប់ការ ប្រមូលផ្តុំគ្នានោះទេ។ តាមធម្មតា អាជ្ញាធរតាមគ្រប់លំដាប់ថ្នាក់មិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់ គណបក្សដឹកនាំប្រទេសទេ ។

របាយការណ៍ដែលគួរឲ្យទុកចិត្តជាច្រើន បានឲ្យដឹងថា ពេលខ្លះ រដ្ឋាភិបាលរារាំងមិនឲ្យសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលរៀបចំពិធីជាសាធារណៈទាក់ទងនឹងសិទ្ធិមនុស្ស ដោយលើកហេតុផលថា ក្រុម ទាំងនោះមិនបានទទួលការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន តែច្បាប់មិនតម្រូវឲ្យមានការយល់ព្រមជាមុន សំរាប់ធ្វើពិធីបែបនេះទេ ។ អាជ្ញាធរលើកហេតុផលពីតម្រូវការឲ្យមាន «ស្ថិរភាព» និង «សន្តិសុខសាធារ ណៈ» ដែលជាពាក្យមិនមាននិយាយនៅក្នុងច្បាប់ ហើយដូច្នេះ ត្រូវបានបកស្រាយតាមចិត្ត សម្រាប់ការ មិនផ្តល់ការអនុញ្ញាត។ អាជ្ញាធររដ្ឋាភិបាលពេលខ្លះ ថែមទាំងលើកឡើងពីខនៅក្នុងច្បាប់អង្គការ ដើម្បី រារាំងអង្គការ សមាគមមិនឲ្យរៀបចំពិធីជាសាធារណៈ ឬបំបែកការប្រជុំឬការរៀនសូត្រ ដែលគេគិតថា ប្រឆាំងនឹងរដ្ឋាភិបាល។

ទោះបីជាមានការរឹតត្បិតទាំងនេះក្តី តែផ្នែកសារព័ត៌មានបានរាយការណ៍ពីការតវ៉ាជាសាធារណៈ ជាច្រើន ដែលភាគច្រើនទាក់ទងនឹងដីធ្លី ឬជម្លោះដីធ្លី។ ក្នុងករណីខ្លះ នគរបាលបំបែកហ្វូងមនុស្សដែល ប្រមូលផ្តុំគ្នាដោយគ្មានការអនុញ្ញាត ដោយក្នុងករណីខ្លះ បណ្តាលឲ្យមានរបួសតិចតួចដល់បាតុករ។ នៅ ក្នុងករណីផ្សេងទៀត នគរបាលបានប្រើកម្លាំងប្រឆាំងនឹងបាតុករ បន្ទាប់ពីពួកគេធ្វើអោយស្ទះចរាចរ គំរាមប្រើឬប្រើហិង្សា ឬមិនព្រមស្តាប់ការបញ្ជាឲ្យបំបែកគ្នា។

បើយោងតាមរបាយការណ៍រួមគ្នា ដែលចេញនៅខែសីហា របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) អង្គការអាដហុក អង្គការ American Center for International Labor Solidarity និង International Center for Not- for- Profit Law គិតពីខែមេសា ឆ្នាំ ២០១៧ ដល់ខែមិនា មាន ៤៨ ករណី នៃការរារាំងដោយអាជ្ញាធរ មិនឲ្យអង្គការ NGO ធ្វើការប្រជុំ បើកវគ្គរៀនសូត្រ ឬប្រមូលផ្តុំគ្នា ដោយសារ ច្បាប់ស្តីពីអង្គការ សមាគម។ របាយការណ៍នេះថែមទាំងកត់ត្រា ការដាក់កំហិតចំនួន ៥៣៩ លើកដោយរ ដ្ឋាភិបាល និងស្ថាប័នភាគីទី ៣ ដែលមានការទាក់ទងជាមួយរដ្ឋាភិបាល លើសេរីភាពជាមូលដ្ឋាន ពីខែ មេសា ឆ្នាំ ២០១៧ ដល់ខែមិនា ដោយមានកំណើនលើសឆ្នាំមុនចំនួន ៥២%។ ថ្វីបើការរឹតត្បិតភាគច្រើន មាននៅភ្នំពេញក្តី តែក៏មានផងដែរនៅតាមគ្រប់ខេត្ត លើកលែងខេត្តព្រៃវែង និងខេត្តកែប។ ពេលខ្លះ អាជ្ញាធរប្តឹងអ្នកធ្វើការតវ៉ាដោយសន្តិភាព។ នៅថ្ងៃទី ១៤ ខែកុម្ភៈ អាជ្ញាធរបានចាប់ខ្លួនមេសហជីព ៤ នាក់ ហើយបានចោទពួកគេពីបទរៀបចំកូដកម្មខុសច្បាប់ នៅរោងចក្រ Cosmo Textile Factory នៅ ខេត្តកណ្តាល។ នៅខែតុលា ឆ្នាំ ២០១៧ អាជ្ញាធរបានចាប់មនុស្ស ៥ នាក់ ដែលបានរៀបចំចែកចាយខិត ប័ណ្ណ នៅក្នុងពេលបុណ្យអុំទូក ដើម្បីអំពាវនាវឲ្យមានការធ្វើបាតុកម្មទាមទារឲ្យរដ្ឋាភិបាលដោះលែងអ្នក ទោសនយោបាយ។ នៅថ្ងៃដដែលនោះ តុលាការក្រុងភ្នំពេញបានកោះហៅ ឡេង សេងហុង ប្រធានសហព័ន្ធ និស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា ពីបទចោទញុះញង់ឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋ ដោយអំពាវនាវឲ្យសាធារណ ជនធ្វើការតវ៉ា ប្រសិនបើគណបក្ស CNRP ត្រូវបានរំលាយ។

មន្ត្រីយោធា និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ រួមទាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកអភិបាល រាជធានីភ្នំពេញ ឃួង ស្រេង អ្នកនាំពាក្យគណបក្ស CPP លោក សុខ ឥសាន អ្នកនាំពាក្យក្រុមប្រឹក្សារដ្ឋ មន្ត្រី លោក ផៃ ស៊ីផាន អគ្គមេបញ្ជាការកងទ័ព លោក ប៉ុល សារឿន បានព្រមានសាធារណជនមិនអោយ

ប្រមូលផ្តុំឬធ្វើបាតុកម្ម នៅក្នុងទីក្រុង នៅក្នុងសវនាការក្តីមេដឹកនាំបក្សប្រឆាំង លោក កឹម សុខា បន្ទាប់ពីមានការចាប់ខ្លួនលោក កាលពីខែកញ្ញា ឆ្នាំ ២០១៧។

នៅខែមេសា គជប បានគំរាមកាត់ទោសអ្នកដែលអំពាវនាវឲ្យអ្នកបោះឆ្នោតធ្វើពហិកាការបោះឆ្នោត។ នៅខែមិថុនា គជប បានផ្ញើសារតាមទូរស័ព្ទដៃ ដោយហាមមិនឲ្យ «រិះគន់ វាយប្រហារ ឬប្រៀបធៀបគោលនយោបាយរបស់គណបក្សមួយ ទៅគណបក្សដទៃទៀត» ។ មន្រ្តីរដ្ឋាភិបាល បានគំរាមកំហែងថា អ្នកដែលមិនទៅបោះឆ្នោត តែយកថ្នាំមកជ្រលក់ម្រាមដៃបន្លំថា បានបោះឆ្នោតនឹងត្រូវទទួលពិន័យ។

## សេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះជាប់លាប់ទេ ពិសេសទាក់ទងនឹងសិទ្ធិកម្មករ (សូមមើលត្រង់ផ្នែក ៧.ក) ។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល តម្រូវឲ្យគ្រប់អង្គការ សមាគមទាំងអស់មានអព្យាក្រិតភាពផ្នែកនយោបាយ ដែលការនេះមិនត្រឹមតែរឹតត្បិតលើសិទ្ធិក្នុងការចូលរួមតែប៉ុណ្ណោះទេ តែថែមទាំងរឹតត្បិតសិទ្ធិនៃអង្គការទាំងនោះ នៅក្នុងការសំដែងមតិដោយសេរីទៀតផង។

នៅខែមិថុនា ឆ្នាំ ២០១៧ លោកនាយករដ្ឋមន្រ្តី ហ៊ុន សែនបានបញ្ជាឲ្យក្រសួងមហាផ្ទៃរំលាយបន្ទប់ស្ថានការណ៍ របស់ក្រុងអង្គការNGO ចំនួន៤០ ដែលភាគច្រើនធ្វើការផ្នែកសិទ្ធិមនុស្ស បន្ទាប់ពីអង្គការទាំងនោះបានចេញលទ្ធផលរកឃើញទាក់ទងនឹងដំណើរការបោះឆ្នោតឃុំនៅថ្ងៃ ៤ មិថុនា។ បន្ទប់ស្ថានការណ៍ បានរងការចោទថា បានរំលោភលើច្បាប់ស្តីពីអង្គការ សមាគម ដោយសារមិនបានចុះបញ្ជីការជាអង្គការមិនមែនរដ្ឋាភិបាល (ថ្វីបើអង្គការនិមួយៗក្នុងចំណោមអង្គការទាំង ៤០ នោះបានចុះបញ្ជីការហើយក្តី) និងពីបទរំលោភលើបញ្ញាតិនៃច្បាប់នេះស្តីពីអព្យាក្រិតភាពផ្នែកនយោបាយ។ បន្ទាប់ពីអង្គការ COMFREL ដែលជាអង្គការ NGO ឈានមុខគេនៅក្នុងបន្ទប់ស្ថានការណ៍ បានប្រកាសថា ខ្លួននឹងធ្វើការសង្កេតបរិយាកាសបោះឆ្នោតក្រៅផ្លូវការ ដោយមិនចូលទៅក្នុងស្ថានីយបោះឆ្នោត អង្គការនេះបានទទួលការព្រមានពីក្រសួងមហាផ្ទៃថា អ្នកស្ម័គ្រចិត្តអង្គការនេះទាំងអស់ដែលត្រូវបានឃើញថា ធ្វើការសង្កេតការបោះឆ្នោត នឹងត្រូវទទួលរងការពិន័យតាមច្បាប់។

នៅខែកញ្ញា ឆ្នាំ ២០១៧ ក្រសួងមហាផ្ទៃបានលុបចោលការចុះបញ្ជីនៃ អង្គការមាតាធម្មជាតិ (Mother Nature) ដែលជាអង្គការមួយ ធ្វើការការពារបរិស្ថាន ដោយមិនបានផ្តល់ការពន្យល់ទេ ដោយគ្រាន់តែចេញលិខិតមួយបញ្ជាក់ពីអំណាចរបស់ក្រសួងមហាផ្ទៃក្នុងការធ្វើដូច្នេះ ៖ «ឧបនាយករដ្ឋមន្រ្តីនិងជារដ្ឋមន្រ្តីក្រសួងមហាផ្ទៃ (ស ខេង) សម្រេចចិត្តលុបអង្គការមាតាធម្មជាតិ....ចេញពីបញ្ជីនៃអង្គការមិនមែនរដ្ឋាភិបាលនៅក្រសួងមហាផ្ទៃ» ។

នៅខែសីហា អាជ្ញាធរបានបង្ខំឲ្យ វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) បញ្ឈប់ប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា បន្ទាប់ពីអាជ្ញាធររកឃើញថា អង្គការនេះមិនបានចុះបញ្ជីត្រឹមត្រូវជាមួយក្រសួងការបរទេស (ទោះបីជាមានអនុស្សារណៈយោគយល់គ្នាត្រឹមត្រូវជាមួយ គជប ក្តី)។

នៅខែកញ្ញា ឆ្នាំ ២០១៧ ក្រសួងមហាផ្ទៃបានផ្អាកផងដែរ នូវការងាររបស់អង្គការ NGO មួយផ្នែកសិទ្ធិមនុស្ស ដែលមាន អង្គការសមធម៌កម្ពុជា (Equitable Cambodia) ដោយសារអ្វីដែលក្រសួងចោទថា រំលោភលើលក្ខខន្តិកៈរបស់អង្គការខ្លួនឯង និងការខកខានមិនបានអោយក្រសួងដឹងពីបញ្ជីបុគ្គលិកចុងក្រោយបំផុតរបស់ខ្លួន។ ទីបំផុត ក្រសួងបានអនុញ្ញាតឲ្យអង្គការនេះបើកឡើងវិញ នៅខែកុម្ភៈ។

បញ្ញាតិដែលចែងមិនច្បាស់នៅក្នុងច្បាប់មួយចំនួនហាមប្រាមសកម្មភាពណាទាំងអស់ដែលអាច «ធ្វើឲ្យខូចដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ» ឬប៉ះពាល់ដល់ «សន្តិសុខជាតិ សាមគ្គីជាតិ ប្រពៃណី និងវប្បធម៌នៃសង្គមជាតិកម្ពុជា» ។ អង្គការសង្គមស៊ីវិលបានសំដែងកង្វល់ចំពោះបទបញ្ញាតិដែលចែងមិនច្បាស់ ថា បានបង្កើតឲ្យមានការប្រឈមខ្លាំងនឹងការរឹតត្បិតតាមចិត្ត លើសិទ្ធិរបស់អង្គការ សមាគម។ យោងតាមអ្នករិះគន់ ច្បាប់អង្គការ និងច្បាប់សហជីព (មើលផ្នែក៧.ក) ចែងពីដំណើរការចុះបញ្ជីស្មុគស្មាញ និងច្រើនជំហាន ហើយខ្វះការការពារផ្នែករដ្ឋបាល ដែលជាការធ្វើឲ្យដំណើរការនៃការចុះ

បញ្ជីរងលក្ខណៈនយោបាយ។ ច្បាប់នេះថែមទាំងកំណត់ឲ្យមានការធ្វើរបាយការណ៍យ៉ាងតឹងតែង ស្តីពីថវិកា និងសកម្មភាព រួមទាំងការត្រូវបង្ហាញសំណើសុំថវិកាដែលបានទទួលថវិកា កិច្ចព្រមព្រៀងលើថវិកាជំនួយ ឬកិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុ។ កាតព្វកិច្ចបន្ថែមទៀតរួមមានការបង្ហាញសំណើសុំថវិកាដែលបានទទួលការយល់ព្រម កិច្ចព្រមព្រៀងលើថវិកាឬអំណោយថវិកា និងគណនេយ្យធនាគាររបស់អង្គការសមាគម។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជារបស់បណ្តុំនៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បាននិយាយកាលពីខែកក្កដាថា ជាទូទៅ អង្គការក្រៅរដ្ឋាភិបាល ខ្វះការណែនាំពីរដ្ឋាភិបាល ស្តីពីការគោរពតាមលក្ខខណ្ឌទាមទារ។

## គ. សេរីភាពសាសនា

ចំពោះសេចក្តីរៀបរាប់លម្អិតស្តីពីសេរីភាពសាសនា សូមមើល*របាយការណ៍ស្តីពីសេរីភាពសាសនា*តាមគេហទំព័រ www.state.gov/religiousfreedomreport/ ។

## ឃ. សេរីភាពដើរហើរ

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស ការធ្វើអន្តោប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។

<u>និរទេស</u>៖ នៅឆ្នាំមុនៗ អ្នករិះគន់រដ្ឋាភិបាល និងអ្នកនយោបាយនៃគណបក្សប្រឆាំងច្រើនតែនិរទេសខ្លួនឯងទៅបរទេស។ នៅក្នុងករណីខ្លះ រដ្ឋាភិបាលចាត់វិធានការរាំងខ្ទប់មិនឲ្យអ្នកធ្វើនិរទេសខ្លួនត្រឡប់មកវិញ។ អាជ្ញាធរថៃបានចាប់បញ្ជូនសកម្មជនការងារក្នុងស្រុកមួយ ដែលបានទទួលឋានៈជាជនភៀសខ្លួនហើយនៅប្រទេស ឲ្យត្រឡប់មកកម្ពុជាវិញ នៅខែកុម្ភៈ។

### ការការពារជនភៀសខ្លួន

<u>ការចាប់បញ្ជូនជនភៀសខ្លួនត្រឡប់វិញ</u>៖ ដោយចោទថា ការទាមទារសុំសិទ្ធិជ្រកកោនពួកគេខ្សោយ និងថា ពួកគេគឺជា “ជនអន្តោប្រវេសន៍សេដ្ឋកិច្ច” រដ្ឋាភិបាលបានចាប់ផ្តើមដំណើរការចាប់បញ្ជូនត្រឡប់ទៅប្រទេសដើមវិញនូវ ជនជាតិវៀតណាមកាន់សាសនាគ្រឹះក្រុមម៉ុងតាញ៉ា ។ ទាំងនេះគឺជាករណីចុងក្រោយនៃការបញ្ជូនជនជាតិម៉ុងតាញ៉ា ចំនួនយ៉ាងហោចណាស់ ១៤០ នាក់ទៅប្រទេសវៀតណាមវិញ គិតតាំងពីឆ្នាំ ២០១៥ មក។ អង្គការមិនមែនរដ្ឋាភិបាលខ្លះបាននិយាយថា ចំណាត់ការនេះគឺបណ្តាលមកពីមានការគាបសង្កត់ពីរដ្ឋាភិបាលវៀតណាម។ បន្ទាប់ពីមានសេចក្តីថ្លែងការណ៍រិះគន់កាលពីខែសីហា ឆ្នាំ ២០១៧ របស់លោកស្រី Rhona Smith អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ដែលនៅក្នុងនោះ លោកស្រីបានទទួលស្គាល់ភាពត្រឹមត្រូវនៃការអះអាងសុំសិទ្ធិជ្រកកោនអ្នកម៉ុងតាញ៉ា វៀតណាមដែលកាន់សាសនាគ្រឹះ ៣៦ នាក់ រដ្ឋាភិបាលកម្ពុជាបានបញ្ជូនពួកគេចំនួន ៧ នាក់ទៅប្រទេសទី ៣។ រដ្ឋាភិបាលបានបដិសេធសេចក្តីថ្លែងរបស់អ្នករាយការណ៍ពិសេស ហើយបានថ្កោលទោសលោកស្រី ចំពោះជាការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន។

<u>លទ្ធភាពទទួលបានការជ្រកកោន</u>៖ ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ រដ្ឋាភិបាលមិនបានផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធនេះដល់អ្នកសុំសិទ្ធិជ្រកកោន និងជនភៀសខ្លួនទាំងអស់ទេ (សូមអានខាងលើ)។

ការងារ៖ អ្នកដែលបានទទួលឋានៈជាជនភៀសខ្លួន គ្មានសិទ្ធិធ្វើការទេ។

លទ្ធភាពទទួលបានការបម្រើផ្នែកសេវាសាធារណៈជាមូលដ្ឋាន៖ អ្នកដែលបានទទួលឋានៈជាជនភៀសខ្លួន គ្មានលទ្ធភាពទទួលបានការបម្រើផ្នែកសេវាសាធារណៈជាមូលដ្ឋានទ រួមទាំងសេវាសាធារណៈ និងសេវាធនាគារផងដែរ។

ដំណោះស្រាយយូរអង្វែង៖ យោងតាមកិច្ចព្រមព្រៀងជាមួយប្រទេសអូស្ត្រាលី នៅឆ្នាំ ២០១៤ រដ្ឋាភិបាលបានទទួលយកឲ្យស្នាក់នៅ នូវជនភៀសខ្លួនចំនួន ៧ នាក់ ដែលត្រូវបានគេឃុំ ក្នុងពេលដែលពួកគេស្វែងរកសិទ្ធិជ្រកកោននៅប្រទេសអូស្ត្រាលី ។ ជនភៀសខ្លួនចុងក្រោយគេបានមកដល់នៅខែមេសា ឆ្នាំ ២០១៧ ។ ក្នុងចំណោមអ្នកទាំង ៧ មាន ៣ នាក់ ដែលជាជនជាតិ Rohingya ពីប្រទេសភូមា បានបន្តស្នាក់នៅកម្ពុជាជាបន្ត ចំណែក ៤ នាក់ទៀត ដែលមានម្នាក់មកពីភូមា និង ៣ នាក់ទៀតមកពីអ៊ីរ៉ាក់ បានសម្រេចចិត្តត្រឡប់ទៅប្រទេសរបស់គេវិញ។ ថ្វីបើជនជាតិ Rohingya ទាំង ៣ នាក់បានសម្រេចចិត្តនៅកម្ពុជាក្តី តែគ្មានវិធីច្បាស់លាស់សំរាប់ឲ្យជនភៀសខ្លួនទទួលបានសញ្ជាតិទេ។ ម្នាក់ក្នុងចំណោមអ្នកភៀសខ្លួនទាំងនោះដែលបន្តស្នាក់នៅ បានគំរាមធ្វើកូដកម្មបង្អត់អាហារខ្លួនឯង បើអាជ្ញាធរមិនឲ្យគាត់បានជួបជុំជាមួយគ្រួសារគាត់ឡើងវិញទេ។

**ជនគ្មានប្រទេស [ជនគ្មានរដ្ឋ]**

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេស។ គ្មានទិន្នន័យថ្មី ដែលគួរឲ្យទុកចិត្តបានស្តីពីចំនួន ឬប្រជាសាស្ត្រនៃអ្នកគ្មានរដ្ឋទេ តែអង្គការ UNHCR បាននិយាយថា ពួកគេភាគច្រើនជាអាណិកជនវៀតណាម។ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាពដើម្បីផ្តល់ឱកាសដល់ជនទាំងនោះឲ្យទទួលបានសញ្ជាតិឡើយ ។ (សូមមើលផ្នែកទី ៦ ស្តីពីកុមារ)។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺ កង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនសូវបានទទួលបានការងារដែលមានលក្ខណៈផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣. សេរីភាពក្នុងការចូលរួមក្នុងដំណើរការនយោបាយ

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនតាមរយៈការបោះឆ្នោតជាទៀងទាត់ ដោយសេរី និងយុត្តិធម៌ ដោយផ្អែកលើសិទ្ធិបោះឆ្នោតជាសាកល និងស្មើភាព។ នៅក្នុងឆ្នាំ ២០១៧ សភាបានធ្វើវិសោធនកម្មលើច្បាប់គណបក្សចំនួន ២ ដង ដោយម្តងៗ ពង្រីកហេតុផលសំរាប់ឲ្យរដ្ឋាភិបាលរំលាយគណបក្សនយោបាយ និងហាមបុគ្គលមិនឲ្យកាន់មុខតំណែងដឹកនាំក្នុងគណបក្ស និងជីវិតនយោបាយ។ វិសោធនកម្មទាំងនោះថែមទាំងរឹតត្បិតគណបក្សមិនឲ្យប្រើឯកសារជាសំឡេង ជារូបភាព ឬជាសំណេរ ដែលបានមកពីជនល្មើសដែលតុលាការបានដាក់ទោស។

នៅខែវិច្ឆិកា ឆ្នាំ ២០១៧ តុលាការកំពូលបានលើកពីវិសោធនកម្មថ្មី នៅក្នុងការសម្រេចចិត្តរបស់ខ្លួន ដើម្បីរំលាយគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) បែងចែកកៅអីរបស់គណបក្សនេះ នៅក្នុងសភា និងនៅក្នុងអាជ្ញាធរមូលដ្ឋាន ទៅឲ្យគណបក្សដទៃ ពិសេសឲ្យគណបក្សកាន់អំណាច CPP ហាមប្រាមមេដឹកនាំគណបក្ស CNRP ចំនួន ១១៨ នាក់មិនអោយធ្វើសកម្មភាពនយោបាយចំនួន ៥ ឆ្នាំ។ លោកនាយករដ្ឋមន្ត្រីបានប្រកាសថា ការបែងចែកកៅអីឡើងវិញនេះជាការលើកស្ទួយការប្តេជ្ញាចិត្តតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ចំពោះលទ្ធិប្រជាធិបតេយ្យពហុបក្ស។ តែអ្នកសង្កេតការណ៍មួយចំនួនបានចោទប្រកាន់តុលាការកំពូល ដែលមានប្រធានស្ថិតនៅក្នុងជួរដឹកនាំរបស់គណបក្ស CPP ពីបទមានភាពលំអៀងនយោបាយ ហើយបានចោទសួរពីភាពត្រឹមត្រូវនៃការសម្រេចចិត្តរបស់តុលាការ និងកង្វះការ

ប្រកាន់តាមបទដ្ឋានច្បាប់។ ឧទាហរណ៍ ការសម្រេចហាមប្រាមមិនឲ្យមានគណបក្ស CNRP មានឡើង មុនពេលមេដឹកនាំរបស់បក្សនេះរងការដាក់ទោសដោយតុលាការពីបទចោទអ្វីមួយ ។

**ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ**

ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ៖ ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុត ត្រូវបានធ្វើថ្ងៃទី ២៩ ខែកក្កដា ហើយមានការចូលរួមនៃគណបក្សនយោបាយចំនួន ២០ ដោយគ្មានការចូលរួមគណបក្ស CNRP ដែលជាគណបក្សប្រឆាំងធំជាងគេ។ លើសពីនេះទៀត គណបក្សប្រឆាំងទាំង ១៩ ដែលចូលប្រកួតប្រជែង មានការគាំទ្រតិចហើយមានច្រើនទើបនឹងបង្កើតថ្មី។

ដោយសារមានការធ្លាក់ចុះនៃអង្គភាពសារព័ត៌មានឯករាជ្យ អង្គភាពសារព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយលើសលុប នៅមុនពេលបោះឆ្នោត ពិសេសនៅតំបន់ជនបទដែលអ្នកបោះឆ្នោតភាគច្រើនមិនសូវទទួលបានព័ត៌មានពីផ្នែកសារព័ត៌មានឯករាជ្យតាមអ៊ិនធឺណែត ហើយទទួលបានព័ត៌មានភាគច្រើនពីប្រព័ន្ធផ្សព្វផ្សាយគ្រួសារលោក ហ៊ុន សែន និងគណបក្ស CPP ។

អ្នកបោះឆ្នោតជាច្រើនគូសចោល ជាជាងបោះឆ្នោតឲ្យគណបក្សប្រឆាំងណាមួយ។ បើតាមតួលេខរបស់រដ្ឋាភិបាល មនុស្សចំនួនជិត ៧ លាននាក់ ដែលត្រូវជាចំនួន ៨៣% នៃអ្នកមានសិទ្ធិបោះឆ្នោត បានចេញទៅបោះឆ្នោត។ គណបក្សកាន់អំណាច CPP បានទទួលចំនួន ៤,៨ លានសំលេង ដោយឈ្នះកៅអីទាំង ១២៥ នៅក្នុងរដ្ឋសភា។ អាជ្ញាធរគិតថា សន្លឹកឆ្នោតប្រមាណ ៦ សែនមិនត្រូវបានយកជាបានការ ចំណែកនៅក្នុងការបោះឆ្នោតក្នុងឆ្នាំ ២០១៣ មានតែ ១ សែនសន្លឹកទេ។

ថ្វីបើមានប្រទេសចំនួន ៦ បានចាត់ទុកការបោះឆ្នោតនេះថាមានភាពសេរី យុត្តិធម៌ និងតម្លាភាពក្តី តែអ្នកសង្កេតការណ៍ភាគច្រើនចាត់ទុកដំណើរការបោះឆ្នោតទាំងមូលថាមានកំហុសឆ្គង។ ស្ថានទូត ភាគច្រើននៅកម្ពុជាមិនព្រមធ្វើជាអ្នកសង្កេតការណ៍ផ្លូវការ នៅក្នុងការបោះឆ្នោតនេះទេ។ អង្គការសង្កេតការណ៍បោះឆ្នោតដែលមិនមែនរបស់រដ្ឋ ដោយរួមមានទាំងមជ្ឈមណ្ឌល Carter Center និង Asian Network for Free Elections ក៏បានសម្រេចចិត្តមិនមកធ្វើការតាមដានការបោះឆ្នោតនេះដែរ ពីព្រោះអង្គការទាំងនោះចាត់ទុកថា ការបោះឆ្នោតនេះខ្វះភាពត្រឹមត្រូវជាមូលដ្ឋាន។ គជប បានចោទសហគមន៍អន្តរជាតិថា មានភាពលំអៀង ដោយនិយាយថា សហគមន៍អន្តរជាតិគាំទ្រ គជប តែនៅពេលណាមានការចូលរួមការបោះឆ្នោតរបស់គណបក្ស CNRP តែប៉ុណ្ណោះ។ ដោយគ្មានអ្នកសង្កេតការណ៍ឯករាជ្យដែលគួរអោយទុកចិត្តបាន លទ្ធផលឆ្នោតក៏គេមិនអាចធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ដោយឯករាជ្យបានផងដែរ។

គណបក្សនយោបាយ និងការចូលរួមនយោបាយ៖ ប្រហាក់ប្រហែលនឹង CNRP ដែរ គណបក្សនយោបាយនានាទទួលរងនូវការរើសអើងតាមផ្លូវច្បាប់ ការអនុវត្តច្បាប់មិនស្មើភាព ការគំរាមកំហែង និងការផ្សាយព័ត៌មានដោយមានលំអៀង។ កត្តាទាំងអស់នេះនាំឲ្យគណបក្ស CPP យកផ្តាច់មុខនូវអំណាចនយោបាយ។ អ្នកសង្កេតការណ៍ជាច្រើនបានត្អូញត្អែរថា ការបែកគ្នានៃបក្សប្រឆាំងធ្វើឲ្យគណបក្ស CPP គ្រប់គ្រងទាំងស្រុងលើរដ្ឋសភាជាតិ។ អ្នកកាន់មុខតំណែងជាច្រើននៅក្នុងរដ្ឋាភិបាលត្រូវតែជាសមាជិកនៃគណបក្ស CPP ។

ការចូលរួមរបស់ស្ត្រី និងក្រុមជនជាតិភាគតិច៖ គ្មានច្បាប់ដែលដាក់កំហិតព្រំដែនលើការចូលរួមរបស់ស្ត្រីនិងជនជាតិភាគតិច នៅក្នុងដំណើរការនយោបាយទេ តែវប្បធម៌ប្រពៃណីកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ និងរដ្ឋាភិបាល ។ ទោះបីជាគណបក្ស CPP បានសន្យាម្តងហើយម្តងទៀតថា នឹងបង្កើនតំណាងរបស់ស្ត្រីក្តី តែចំនួនបេក្ខជនជាស្ត្រីដែលជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជាតិនៅខែកក្កដាមានការថយចុះពី ២០% មកត្រឹម ១៥%។ ការបោះឆ្នោតកាលពីខែមិថុនា ឆ្នាំ ២០១៧ ក្រុមប្រឹក្សាឃុំសង្កាត់ តាមពិតទៅ មានការថយចុះពីលទ្ធផល ឆ្នាំ ២០១២។ ការបោះឆ្នោតថ្នាក់មូលដ្ឋាន នៅខែមិថុនា ឆ្នាំ ២០១៧ ឃើញមានជាលើកដំបូង នូវការចូលរួមនៃគណបក្សប្រជាធិបតេយ្យជនជាតិដើមកម្ពុជា ។

**ផ្នែកទី៤ ៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល**

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់ តែងតែប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព ។

<u>អំពើពុករលួយ៖</u> ក្រមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោសចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយ ចែងពីមូលដ្ឋានច្បាប់សម្រាប់ឲ្យក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយទទួល និងស៊ើបអង្កេតបណ្ដឹងទាក់ទងនឹងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមិនសហការឲ្យបានញឹកញាប់ជាមួយសង្គមស៊ីវិល ហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ផ្ទុយទៅវិញ អង្គភាពប្រឆាំងអំពើពុករលួយមានភាពសកម្មនៅក្នុងការដឹកនាំការស៊ើបអង្កេតទៅលើសមាជិកនៃគណបក្សប្រឆាំង ដែលជាការនាំឲ្យគេនាំគ្នាយល់ថា អង្គភាពនេះបម្រើផលប្រយោជន៍របស់គណបក្សកាន់អំណាច។ ផ្ទុយទៅវិញ អង្គភាពនេះមិនដែលស៊ើបអង្កេតសមាជិកជាន់ខ្ពស់នៃគណបក្សកាន់អំណាចទេ។ ឧទាហរណ៍ យោងតាមរបាយការណ៍ស៊ើបអង្កេតចេញខែកក្កដា របស់ទូរទស្សន៍ al-Jazeera អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជា បានរំលោភលើច្បាប់សារជីវកម្មអូស្ត្រាលី ហើយបានគេចពន្ធអូស្ត្រាលីលើភាគហ៊ុនប្រេង តែអាជ្ញាធរកម្ពុជាមិនបានធ្វើការស៊ើបអង្កេតឬកាត់ទោសគាត់ទេ។ មន្ត្រីរាជការត្រូវមានការយល់ព្រមពីប្រធាន មុនពេលឆ្លើយសំណួរផ្លូវច្បាប់ ទាក់ទងនឹងការចោទប្រកាន់រឿងអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល នៅក្នុងសង្គម និងរដ្ឋាភិបាល។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជម្រះក្តី បានទទួលសំណូកពីអ្នករកស៊ី ទាំងស្របច្បាប់ ទាំងខុសច្បាប់។ ពលរដ្ឋតែងតែត្អូញត្អែរជាសាធារណៈអំពីអំពើពុករលួយ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកឲ្យមាន «អំពើពុករលួយដើម្បីរស់» ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាពធ្វើឲ្យអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។

យោងតាមការវាស់ស្ទង់ដែលមានឈ្មោះថា 2016 Global Corruption Barometer តុលាការគឺជាវិស័យដែលពុករលួយជាងគេ នៅក្នុងរយៈពេល ៤ ឆ្នាំជាប់គ្នា ដែលបន្ទាប់មកគឺផ្នែកអនុវត្តច្បាប់។

<u>ការប្រកាសទ្រព្យសម្បត្តិ៖</u> រាជការ រួមទាំងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោតផង តាមច្បាប់ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) ទទួលខុសត្រូវក្នុងការទទួលយកសេចក្តីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាមមានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាន់ខ្ពស់មិនត្រូវបានឲ្យដឹងដល់សាធារណៈទេ ហើយនៅបិទជិតក្នុងស្រោមសំបុត្រ រហូតទាល់តែមានការប្តឹងទាក់ទងនឹងអំពើពុករលួយ។ មានតែសេចក្តីប្រកាសទ្រព្យសម្បត្តិតែមួយគត់ត្រូវបានបើកមើល គឺសេចក្តីប្រកាសរបស់អតីតប្រធានគណបក្ស CNRP កឹម សុខា ។

## ផ្នែកទី៥ ៖ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្ស

មានរបាយការណ៍ជាច្រើនអំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយ មន្ត្រីរដ្ឋាភិបាលលើអ្នកស៊ើបអង្កេត។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិរងកំណើននៃការឃាយឺ គំរាមកំហែង ការតាមដាន និងការសម្លុតពីមន្ត្រីមូលដ្ឋាន និងអ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ។ អង្គការសង្គមស៊ីវិល និងអង្គការពលកម្មមួយចំនួន បាននិយាយក្រោយការឆ្នោតខែកក្កដាថា នគរបាលបានឆ្មក់ចូលការិយាល័យរបស់គេ ហើយផ្នែកពន្ធដារបានស៊ើបអង្កេតគណនេយ្យរបស់គេ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ២៥ នៅក្នុងប្រទេស និងមានចំនួនប្រហែល ១០០ ទៀតដែលផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្សជាផ្នែកមួយនៃការងាររបស់គេនៅក្នុងវិស័យផ្សេងទៀត ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត៖ រដ្ឋាភិបាល ជាទូទៅ បានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ នៅខែមិនា អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី Rhona Smith បានមកធ្វើទស្សនកិច្ចនៅកម្ពុជាជា ចំនួន ១០ ថ្ងៃ។ នៅក្នុងការប្រជុំរបស់លោកស្រីជាមួយរដ្ឋសភាជាតិ គជប គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង NGO លោកស្រីបានលើកពីកង្វល់ជ្រាលជ្រៅលើការរឹតត្បិតលើផ្នែកសារព័ត៌មាន ការចូលរួមផ្នែកនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ និងការបែងចែកកៅអីសភារបស់គណបក្ស CNRP ទៅឲ្យគណបក្សកាន់អំណាច ដោយនិយាយថា «សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍» មិនអាចកាត់ផ្តាច់ចេញពីកាតព្វកិច្ចសិទ្ធិមនុស្សទេ។ រដ្ឋាភិបាលច្រើនតែមិនព្រមជួបប្រជុំថ្នាក់ខ្ពស់ ជាមួយតំណាងនៃអង្គការសហប្រជាជាតិ ហើយមិនឲ្យពួកគេជួបជាមួយមន្ត្រីបក្សប្រឆាំង ដោយរួមទាំងលោក កឹម សុខា ផងដែរ។ អ្នកនាំពាក្យរបស់រដ្ឋាភិបាលតែងតែរិះគន់តំណាងពិសេសនៃអង្គការសហប្រជាជាតិជាសាធារណៈ ចំពោះការនិយាយរបស់គេស្តីពីបញ្ហានានាផ្នែកសិទ្ធិមនុស្ស។

ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល៖ រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែក ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង នៅក្រោមព្រឹទ្ធសភា និងរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រគល់របាយការណ៍របស់ រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះរបាយការណ៍របស់ស្ថាប័នរដ្ឋាភិបាល និងអង្គការអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបានចាត់ទុកថា គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានប្រសិទ្ធភាពការងារនៅមានកំរិត ហើយបានរិះគន់តួនាទីរបស់គេនៅក្នុងការនិយាយការពារការបង្ក្រាបរបស់រដ្ឋាភិបាល ទៅលើសង្គមស៊ីវិល និងអ្នកប្រឆាំង។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ បានបន្តធ្វើការស៊ើបអង្កេត និងដាក់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើយង់ឃ្នង ដែលត្រូវបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលនៅក្នុងនោះ ប្រជាជននៅក្នុងប្រទេសចំនួនជិត ១ ភាគ ៤ បានស្លាប់។ ECCC គឺជាតុលាការកូនកាត់ ដោយមានបុគ្គលិក និងចៅក្រមជាតិ និងអន្តរជាតិ ហើយគ្រប់គ្រងដោយច្បាប់ក្នុងស្រុករបស់កម្ពុជាផង និងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិផង។ នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៦ ECCC បាន ដាក់ទោសទៅលើឈ្មោះ នួន ជា និងខៀវ សំផន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុង Geneva ឆ្នាំ ១៩៤៩។ សាលក្រមដាក់ទោសរបស់តុលាការនេះគឺជាការទទួលស្គាល់ជាផ្លូវការលើកដំបូងថា ឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហមគឺជាបទប្រល័យពូជសាសន៍ ដូចដែលមានចែងនៅក្រោមច្បាប់អន្តរជាតិ។ មនុស្សប្រហែល ២ លាននាក់ត្រូវបានគេជឿថា បានស្លាប់ ដោយសារពួកខ្មែរក្រហម នៅចន្លោះពេលពីឆ្នាំ ១៩៧៥ និង ១៩៧៩។

## ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

### ស្ត្រី

<u>ការរំលោភសេពសន្ថវៈ និងហឹង្សាក្នុងគ្រួសារៈ</u> ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាធំ។ ច្បាប់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ អំពើរំលោភសេពសន្ថវៈត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវៈ ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា "អំពើរំលោភសេពសន្ថវៈ" "ការបង្ករបួសស្នាម" ឬ "ការបំពារបំពានមិនសមរម្យ"បាន។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ មិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ គេអាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសហិង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំរហូតដល់ ១៥ឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបានរាយការណ៍ថា អំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ កើតមានជាទូទៅ។ អំពើហិង្សាក្នុងគ្រួសារនិងការរំលោភផ្លូវភេទច្រើនតែមិនត្រូវបានគេរាយការណ៍អស់ ដោយសារជនរងគ្រោះខ្លាចការសងសឹកដោយជនល្មើស ការរើសអើងនៅក្នុងសង្គម និងការដែលគេមិនទុកចិត្តប្រព័ន្ធតុលាការ។ នៅក្នុងចំណោមមន្ត្រីតុលាការ មានចំនួននារីតិចតួច។ ១៤% នៃចៅក្រម ១២% នៃព្រះរាជអាជ្ញា ២០% នៃមេធាវី។ អង្គការ NGO បាននិយាយថា អាជ្ញាធរមិនសូវប្រឹងប្រែងខ្លាំងក្នុងការអនុវត្តច្បាប់គ្រួសារទេ ហើយជៀសវាងការពាក់ព័ន្ធក្នុងជម្លោះក្នុងគ្រួសារ។ មានតែ ២០% នៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានតាមដានពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៦ បានឈានដល់ដំណើរការក្តីព្រហ្មទណ្ឌ។

ការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ ជាញឹកញាប់ បណ្តាលអោយស្លាប់ៈ អង្គការ NGO មួយបាននិយាយថា មានការសម្លាប់ចំនួន ១០ ករណី នៅក្នុងការសង្កេតពីខែមករា ដល់ខែមិថុនា លើករណីអំពើហឹង្សាក្នុងគ្រួសារចំនួន ៣៩ និងករណីរំលោភផ្លូវភេទចំនួន ១៨។ នៅក្នុងចំណោមករណីទាំង ៥៧ នេះ អាជ្ញាធរបានចាប់ខ្លួនជនល្មើសបានតែ ២៣ នាក់ទេ។ យោងតាមរបាយការណ៍ឆ្នាំ ២០១៧ របស់អង្គការ NGO ផ្នែកសិទ្ធិមនុស្ស ទាំងអាជ្ញាធរ ទាំងសាធារណជន ជាទូទៅ មិនចាត់ទុកអំពើហឹង្សាក្នុងគ្រួសារថាជាបទល្មើសព្រហ្មទណ្ឌទេ ។

នៅខែកក្កដា ឆ្នាំ ២០១៧ ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារីបានចាប់ផ្តើមអនុវត្តក្រមអាកប្បកិរិយាសំរាប់ប្រព័ន្ធផ្សព្វផ្សាយ ទាក់ទងនឹងហិង្សាទៅលើនារី។ ក្រមនេះហាមប្រាមការបោះពុម្ពព័ត៌មាន ដែលរួមទាំងរូបនៃជនរងគ្រោះ ការបង្ហាញពីការស្លាប់ របួស ឬភាពអាក្រាតរបស់ជនរងគ្រោះ ការប្រើពាក្យប្រមាថទៅលើស្ត្រី។ ក្រសួងកិច្ចការនារី ថែមទាំងបានប្រកាសពីប្រព័ន្ធធ្វើសេចក្តីរាយការណ៍ នៅក្នុងជួររដ្ឋាភិបាល ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះហិង្សាទៅលើស្ត្រី។ ក្រសួងកិច្ចការនារី ថែមទាំងបានធ្វើការសម្របសម្រួលជាមួយអង្គការ NGO មួយចំនួន និងផ្នែកសារព័ត៌មានខ្លះ ដើម្បីធ្វើកម្មវិធីតាមវិទ្យុ និងទូរទស្សន៍ស្តីពីបញ្ហាទាក់ទងនឹងស្ត្រី។

<u>ការបៀតបៀនផ្លូវភេទៈ</u> ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០ ០០០រៀលទៅ ៥០០ ០០០រៀល (២៥ ទៅ ១២៥ ដុល្លារអាមេរិក)។ ការសិក្សាមួយដែលត្រូវបានធ្វើដោយអង្គការ CARE International បានរកឃើញថា ជិត១ ភាគ ៣ នៃកម្មការិនីរោងចក្រកាត់ដេរធ្លាប់ត្រូវបានគេបៀតបៀនផ្លូវភេទ នៅកន្លែងធ្វើការរបស់គេ នៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។

<u>ការបង្ខិតបង្ខំក្នុងការគ្រប់គ្រងចំនួនប្រជាជនៈ</u> គ្មានសេចក្តីរាយការណ៍ពីរំលូតកូនដោយបង្ខំ ឬវិធីគ្រប់គ្រងកំណើតដោយមិនស្ម័គ្រចិត្តទេ។

ការរើសអើង៖ រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែ ប្រពៃណីវប្បធម៌ និងការទទួលខុសត្រូវក្នុងការមើលកូនបានកម្រិតលទ្ធភាពរបស់ស្ត្រី ក្នុងការឈានទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬបានការងារធ្វើ (សូមមើលផ្នែក ៧ ឃ)។

**កុមារ**

ការចុះសំបុត្រកំណើត៖ តាមច្បាប់ កុមារទទួលសញ្ជាតិពីកំណើតពីឪពុកម្តាយដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជាតាមរយៈមធ្យោបាយផ្សេងទៀតតាមផ្លូវច្បាប់។ ជនជាតិខ្មែរដើមត្រូវបានចាត់ទុកថាជាពលរដ្ឋ។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ពិសេសដោយសារកង្វះការយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជីកំណើត និងអំពើពុករលួយច្រើន របស់អាជ្ញាធរមូលដ្ឋាន។ ចាប់ពីខែមករាមក អាជ្ញាធរលែងយកកម្រៃចំពោះការចុះបញ្ជីកំណើត។

ការខកខានមិនបានចុះបញ្ជីកំណើតនាំឲ្យមានការរើសអើង រួមទាំងក្នុងការមិនផ្តល់សេវាសាធារណៈផងដែរ។ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិច្រើនត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលត្រូវបានគេផាត់ចេញ បានរាយការណ៍ថា ជារឿយៗ កុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារ បាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា អ្នកទាំងនេះច្រើនតែគ្មានលទ្ធភាពក្នុងការទទួលបានការងារធ្វើ ការមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចូលរួមបោះឆ្នោត ឬការប្រើប្រាស់ប្រព័ន្ធច្បាប់។

ការអប់រំ៖ ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាកាតព្វកិច្ចត្រូវតែរៀនទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ។ អ្នកខ្លះទៀតចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗគ្រួសារដែលមានធនធានមានកម្រិត ផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី ពិសេសនៅតំបន់ជនបទ។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់ទីក្រុង ចំណែកការចូលរៀនរបស់ក្មេងប្រុសនៅក្រោយថ្នាក់បឋមសិក្សា មានចំនួនធ្លាក់ចុះច្រើនគួរសម នៅតំបន់ជនបទ។

ការរំលោភធ្វើបាបកុមារ៖ បើតាមអ្នកសង្កេតការណ៍ ការរំលោភធ្វើបាបកុមារច្រើនកើតមាន ហើយការប្តឹងប្រឆាំងនឹងជនប្រព្រឹត្តកម្រមានណាស់។ បើយោងតាមរបាយការណ៍របស់អង្គការ UNICEF ស្តីពីហិង្សាលើកុមារ កុមារកម្ពុជាម្នាក់ក្នុងចំណោម ២ នាក់ធ្លាប់រងហិង្សាខ្លាំង។ ការរំលោភផ្លូវភេទលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ហើយសេចក្តីរាយការណ៍ស្តីពីបទល្មើសនេះឃើញមានច្រើនឡើងៗ នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ការរំលោភសេពសន្ថវៈលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។

ការឆាប់រៀបអាពាហ៍ពិពាហ៍ និងការបង្ខំអោយរៀបអាពាហ៍ពិពាហ៍៖ អាយុគ្រប់ការតាមច្បាប់សម្រាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ តែកុមារអាយុត្រឹម ១៦ ឆ្នាំអាចរៀបការដោយស្របច្បាប់បាន បើមានការយល់ព្រមពីឪពុកម្តាយ។ ឪពុកម្តាយ សមាជិកសហគមន៍ និងអ្នកនយោបាយមិនចាត់ទុកអាពាហ៍ពិពាហ៍កុមារថា ជាបញ្ហាទេ ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារៈ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ ឆ្នាំ គឺជាអំពើខុសច្បាប់។ រដ្ឋាភិបាលបានបន្តឆ្មក់ផ្ទះបន ដើម្បីរកមើល និងប្រមូលជនរងគ្រោះដោយសារការជួញដូរផ្លូវភេទជាកុមារ ថ្វីបើភាគច្រើននៃការជួញដូរផ្លូវភេទលើកុមារមានការលាក់បាំង មាននៅតាមកន្លែងបំរើផ្លូវភេទ «ដោយមិនផ្ទាល់» ដូចជាតាមបៀរហ្គាដិន ហាងម៉ាស្សា កន្លែងកែសម្ផស្ស បារខារ៉ាអូខេ និងកន្លែងមិនមែនធ្វើពាណិជ្ជកម្មនានា។ នគរបាលបន្តស៊ើបអង្កេតលើករណីជួញដូរកុមារ នៅតាមផ្ទះបន ឬក្នុងករណីដែលជនរងគ្រោះមកប្តឹងដោយផ្ទាល់ តែមិនធ្វើការលើករណីស្មុគស្មាញខ្លាំងទេ ឧទាហរណ៍ ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ិនធឺណែត។ រដ្ឋាភិបាលមិនអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ នៅក្នុងការស៊ើបអង្កេតលើការជួញដូរទេ ដែលជាការធ្វើអោយនគរបាលច្រើនមិនអាចចាប់ឲ្យអ្នកប្រព្រឹត្តិការជួញដូរលើកុមារទទួលខុសត្រូវបានទេ។

ប្រទេសកម្ពុជា នៅតែជាគោលដៅទេសចរណ៍ផ្លូវភេទលើកុមារ។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ដើម្បីកាត់ទោសទាំងអ្នកទេសចរផ្លូវភេទ ទាំងពលរដ្ឋដែលកេងប្រវ័ញ្ចកុមារក្នុងពេស្យាចារ។ ច្បាប់ដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ទៅ ២០ ឆ្នាំ ចំពោះការកេងប្រវ័ញ្ច ជួញដូរផ្លូវភេទលើកុមារ។ ច្បាប់នេះក៏ហាមប្រាមផងដែរនូវការផលិត និងការមានរូបអាសអាភាសកុមារ តែច្បាប់មិនហាមឃាត់ដោយដាក់ទោសព្រហ្មទណ្ឌ ចំពោះការផ្តល់កុមារសំរាប់ការសំដែងភាពអាសអាភាស។

បើយោងតាមអង្គការផ្នែកសិទ្ធិមនុស្សក្នុងស្រុកមួយ ជនប្រព្រឹត្តដែលមានខ្សែរយៈក្នុងរដ្ឋាភិបាលមិនត្រូវបានចាប់ឲ្យទទួលខុសត្រូវ នៅក្រោមច្បាប់ឡើយ ហើយអ្នកជំនាញក្នុងស្រុកបានសំដែងកង្វល់អំពីការខកខានរបស់រដ្ឋាភិបាល ក្នុងការដាក់ទោសឲ្យបានសមស្របទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារ។ អំពើពុករលួយដែលរាលដាលនៅគ្រប់ផ្នែកទាំងអស់ក្នុងរដ្ឋាភិបាល ដាក់កំហិតព្រំដែនយ៉ាងខ្លាំងលើលទ្ធភាពរបស់មន្រ្តីម្នាក់ៗ ក្នុងការចាប់ឲ្យជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារទទួលខុសត្រូវ ហើយរដ្ឋាភិបាលមិនធ្វើការស៊ើបអង្កេតឬកាត់ទោសមន្រ្តីដែលឃុបឃិតឡើយ។

កុមារផ្លាស់ទីលំនៅៈ រដ្ឋាភិបាលបានផ្តល់សេវាមានកម្រិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅមជ្ឈមណ្ឌលស្តារនីតិសម្បទា។ កុមារផ្លាស់ទីលំនៅនៅតែជាបញ្ហាធ្ងន់ធ្ងរ និងកំពុងកើនឡើងខ្លាំងពិសេសដោយការធ្វើចំណាកស្រុកចេញទៅធ្វើការនៅបន្តមាន ហើយកុមារក្នុងចំនួនច្រើនត្រូវបានទុកចោល។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវក្នុងចំនួនប្រហែលជាពី ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញ ដែលគ្មានទំនាក់ទំនងគ្រួសារ ហើយកុមារប្រមាណជាពី ១៥ ០០០ ទៅ ២០ ០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេលយប់។

កុមារនៅតាមមណ្ឌលអង្គការៈ អង្គការ NGO និងអ្នកសង្កេតការណ៍ដទៃទៀតបានចោទថា មជ្ឈមណ្ឌលកុមារកំព្រាឯកជនជាច្រើនគ្មានការគ្រប់គ្រងល្អទេ ហើយមានកុមារអត់កំព្រាច្រើន ដើម្បីទាក់ទាញអំណោយពីជនបរទេស។ បើយោងតាមអង្គការ UNICEF និងការស្រាវជ្រាវមួយដែលធ្វើដោយសាកលវិទ្យាល័យ Columbia មានកុមារក្នុងចំនួនពី ៣៦ ០០០ ទៅ ៤៩ ០០០ នាក់រស់នៅតាមផ្ទះដែលផ្តល់ការថែទាំ ឬមជ្ឈមណ្ឌលកុមារកំព្រា។ ប្រហែល ៨០% នៃកុមារទាំងនេះមានយ៉ាងហោចណាស់ក៏ឪពុក ឬក៏ម្តាយដែរ។ ការថែទាំឲ្យស្នាក់នៅតាមផ្ទះនាំឲ្យមានការលូតលាស់ឬលទ្ធផលសុខភាពទាបសម្រាប់កុមារ ហើយធ្វើអោយពួកគេប្រឈមនឹងការកេងប្រវ័ញ្ច នៅពេលអនាគត។ គ្មានកម្មវិធីការពារកុមារដែលដំណើរការឬទ្រទ្រង់ដោយរដ្ឋ សម្រាប់ផ្តល់ជម្រើសមានសុវត្ថិភាពចំពោះកុមារទេ។

ការចាប់ជំរិតកុមារឆ្លងដែនៈ ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការចាប់កុមារឆ្លងដែនតាម

https://travel.state.gov/content/travel/en/International-Parental-Child-Abduction/for-providers/legal-reports-and-data.html

**ការប្រឆាំងនឹងសាសនាជ្វីស** (Anti-Semitism)

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពី ទង្វើប្រឆាំងនឹងសាសនានេះឡើយ។

**ការជួញដូរមនុស្ស**

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/j/tip/rls/tiprpt/។

**ជនពិការ**

ច្បាប់ហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ទាំងពិការរាងកាយ ទាំងពិការផ្នែកសតិបញ្ញា។ ច្បាប់នេះមិននិយាយពីការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ ក្នុងការធ្វើដំណើរទេ។ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ជាអ្នកទទួលខុសត្រូវរួមក្នុងការការពារសិទ្ធិរបស់ជនពិការ ថ្វីបើច្បាប់កំណត់ដាក់ភារកិច្ចដោយឡែកជាក់លាក់សម្រាប់ក្រសួងដទៃទៀត ដែលរួមមានក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងការពារជាតិ។ រដ្ឋាភិបាលសុំឲ្យគ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់មានកម្មវិធីបកប្រែជាភាសាសញ្ញាអមកម្មវិធីផ្សាយរបស់គេ។ មកដល់ត្រឹមខែមិថុនា មានស្ថានីយ៍ទូរទស្សន៍ធំៗពីរ ដែលមួយជាទូរទស្សន៍រដ្ឋ និងមួយទៀតជាទូរទស្សន៍ឯកជន មានការបកប្រែភាសាជាភាសាសញ្ញា នៅក្នុងកម្មវិធីផ្សាយព័ត៌មានរបស់គេ។

ជនពិការជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ ។

កុមារដែលមានភាពពិការខ្លះៗបានចូលរៀននៅសាលាធម្មតា។ បើយោងតាមក្រសួងអប់រំ កុមារពិការចំនួន ១៩ ០០០ នាក់ បានរៀននៅសាលាបឋមសិក្សា ក្នុងឆ្នាំសិក្សា ២០១៥ -២០១៦។ ក្រសួងបានធ្វើការលើការបណ្តុះបណ្តាលគ្រូស្តីពីវិធីបញ្ចូលសិស្សពិការឲ្យរៀនជាមួយសិស្សមិនពិការ។

កុមារដែលពិការខ្លាំង បានរៀននៅសាលាដោយឡែក ដែលឧបត្ថម្ភដោយអង្គការ NGO នៅភ្នំពេញ។ ការសិក្សាសំរាប់ពួកគេគ្មាននៅក្រៅភ្នំពេញទេ។

ពុំមានការកម្រិតតាមច្បាប់ណាមួយចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការឲ្យចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ ។

**សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច**

អ្នកជំនាញបានទទួលស្គាល់ថាមានប្រតិកម្មមិនល្អទៅលើតួនាទីសេដ្ឋកិច្ចកាន់តែច្រើនឡើង របស់ជនជាតិចិន និងចំនួនកាន់តែច្រើនឡើងនៃជនជាតិចិន នៅក្នុងប្រទេស។ កាសែតជាភាសាខ្មែរមានចុះច្រើន នូវរឿងស្តីពីបទល្មើសដែលប្រព្រឹត្តដោយជនជាតិចិន និងថៅកែចិន នៅកម្ពុជា ដោយរួម

មានទាំងហិង្សាដោយក្រុមយូកូង ការក្លែងក្លាយរបស់ រូបអាសអាភាស ការបើកបរដោយស្រវឹង និងថ្នាំញៀន។ នៅខែកញ្ញា ក្រសួងមហាផ្ទៃបានប្រកាសថា ខ្លួននឹងរៀបចំក្រុមការងារមួយ សំរាប់ដោះស្រាយបទល្មើស ដែលភាគច្រើនប្រព្រឹត្តដោយជនជាតិចិន។

**ជនជាតិដើមភាគតិច**

នៅខែវិច្ឆិកា អង្គការក្នុងស្រុកមួយ បានរាយការណ៍ថា មានសហគមន៍ជនជាតិដើមភាគតិចចំនួនតែ ២៦ ប៉ុណ្ណោះក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច ចំនួន ៤៥៨ ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីពីរដ្ឋាភិបាល ។

**អំពើហិង្សា ការរើសអើង និងអំពើហិង្សាដោយផ្អែកលើប្រភេទនៃចំណង់ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ**

គ្មានច្បាប់ដែលដាក់ទោសចំពោះការរួមភេទនៃមនុស្សភេទដូចគ្នាដោយមានការព្រមព្រៀងគ្នាទេ ហើយក៏គ្មានការរើសអើងជាផ្លូវការចំពោះក្រុមស្រ្តីស្រឡាញ់ស្រ្តី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ និងបុគ្គលប្តូរភេទ (LGBTI) ទេទោះបីជាការរើសអើង និងការពេបជ្រាយនៅតែមាន ជាពិសេសនៅតំបន់ជនបទ។

ជាទូទៅ ក្រុម LGBTI ពុំសូវមានឱកាសទទួលបានការងារធ្វើទេ ដោយសារមានការរើសអើងនិងការផាត់ពួកគេចេញ។ មនុស្សក្នុងក្រុមនេះ ច្រើនតែត្រូវបានគេយាយី និងសម្លុត ដោយសារការងាររបស់គេនៅក្នុងកន្លែងកំសាន្ត និងផ្នែកជួញដូរផ្លូវភេទ។ ពុំមានរបាយការណ៍អំពីការរើសអើងដោយរដ្ឋាភិបាលដោយសារប្រភេទនៃចំណង់ផ្លូវភេទ នៅក្នុងការងារ ភាពជាពលរដ្ឋ ការទទួលបានការសិក្សា ឬការថែទាំសុខភាពទេ ។ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ មនុស្សស្រីស្រឡាញ់ស្រីមាននិយាយច្រើននៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។

អង្គការក្នុងស្រុកមួយដែលធ្វើការផ្អែកសិទ្ធិរបស់ក្រុមមនុស្សនៅក្នុងក្រុម LGBTI បានរាយការណ៍ពីករណីចំនួនជាង ១០០ នៃហិង្សាឬការធ្វើបាបទៅលើសមាជិកក្នុងក្រុមមនុស្សនេះ ដោយរួមមានទាំងហិង្សាប្រព្រឹត្តដោយសមាជិកក្នុងគ្រួសារ។ ការមាក់ងាយ ឬការគំរាមប្រហែលជារារាំងមិនអោយគេហ៊ាននិយាយប្រាប់។

**ការមាក់ងាយក្នុងសង្គមទាក់ទងនឹងជំងឺអេដស៍**

ការសិក្សាបង្ហាញថា មានមនុស្សជាច្រើនមានការរើសអើងនឹងអ្នកជំងឺ និងអ្នកមានផ្ទុកមេរោគអេដស៍។

**ផ្នែកទី៧ ៖ សិទ្ធិកម្មករ**

**ក. សិទ្ធិបង្កើតអង្គការ/សមាគម និងសិទ្ធិចរចាអនុសញ្ញារួម**

ច្បាប់អនុញ្ញាតអោយអ្នកធ្វើការផ្នែកឯកជនបង្កើត និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម។ ច្បាប់ដាក់កំហិតព្រំដែនលើសិទ្ធិក្នុងការធ្វើកូដកម្ម សម្រួលអន្តរាគមរបស់រដ្ឋាភិបាលនៅក្នុងកិច្ចការផ្ទៃក្នុងរបស់សហជីព ផាត់មិនឲ្យកម្មករប្រភេទខ្លះចូលរួមក្នុងសហជីព ហើយអនុញ្ញាតឲ្យភាគីទី៣ ស្វែងរកការរំលាយសហជីព ដោយទន្ទឹមនឹងនោះ ធ្វើការដាក់ពិន័យតិចតួចលើថៅកែ ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវជាមួយកម្មករ។

ច្បាប់ស្មុគស្មាញស្តីពីការចុះបញ្ជីសហជីពមានន័យថា ការទាមទារឲ្យមានការអនុញ្ញាតជាមុនសម្រាប់ការបង្កើតសហជីព។ លក្ខខណ្ឌទាមទារក្នុងការចុះបញ្ជីសហជីពរួមមានការដាក់បញ្ចូលផ្នែក ការស្រង់ឈ្មោះមន្ត្រី និងសមាជិកគ្រួសាររបស់គេ ហើយផ្តល់សេចក្តីលម្អិតទាក់ទងនឹងធនាគារ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ច្បាប់ហាមមិនអោយសហជីពដែលមិនបានចុះបញ្ជីការដំណើរការទេ។ ច្បាប់ក៏បញ្ជាក់ផងដែរថា មានតែសហជីពដែលមាន «ឋានៈតំណាងកម្មករភាគច្រើន» គឺសហជីពធំជាងគេនៅកន្លែងធ្វើការមួយ ទើបអាចធ្វើជាតំណាងកម្មករបាន នៅក្នុងការចរចាអនុសញ្ញារួម។ មន្ត្រីរាជការគ្រូបង្រៀន អ្នកធ្វើការនៅតាមសហគ្រាសរដ្ឋ និងអ្នកធ្វើការផ្នែកធនាគារ ផ្នែកថែទាំសុខភាព និងវិស័យក្រៅផ្លូវការ អាចបង្កើតបានតែ «សមាគម» ទេ មិនអាចបង្កើតសហជីពបានទេ។ ការនេះធ្វើឲ្យគេអាចការពារកម្មករបានតិចជាងសហជីព។

គិតមកត្រឹមខែកញ្ញា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញបទបញ្ជាសម្រាប់អនុវត្តចំនួន ៨ ចំណុច ចំពោះច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ។ យ៉ាងហោចណាស់មានមួយចំណុចមិនទាន់ត្រូវបានចេញ។ ឧទាហរណ៍ នៅខែកក្កដា ក្រសួងបានចេញបទបញ្ជាមួយដោយបំភ្លឺថា សហជីពទាំងអស់អាចតំណាងសមាជិករបស់គេ នៅក្នុងដំណើរការដោះស្រាយការវិវាទរួម។ ក្រសួងថែមទាំងបានចេញបទបញ្ជាមួយទៀត ស្តីពីការជ្រើសរើសតំណាងសហជីពសំរាប់ដោះស្រាយជាមួយថៅកែ ព្រមជាមួយនឹងបទបញ្ជាដែលតម្រូវឲ្យសហជីព និងសមាគមថៅកែផ្ញើរបាយការណ៍ប្រចាំឆ្នាំចំនួន ២ ទៅសមាជិករបស់គេ និងក្រសួង។ របាយការណ៍មួយស្តីពីហិរញ្ញវត្ថុ និងមួយទៀតស្តីពីសកម្មភាពរបស់ខ្លួន។ សហជីពជាច្រើនបានសំដែងកង្វល់ថា គេមិនអាចគោរពបានតាមបទបញ្ជាស្តីពីរបាយការណ៍ហិរញ្ញវត្ថុបានទេ ដែលតម្រូវសហជីពក្នុងមូលដ្ឋានទាំងអស់ធ្វើកំណត់ហេតុហិរញ្ញវត្ថុប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំឆ្នាំ ព្រមទាំងរក្សាសំណៅជាក្រដាសនៃបង្កាន់ដៃ ចំណូលទាំងអស់។

ច្បាប់មានចែងថាកម្មករអាចធ្វើកូដកម្មបាន តែបន្ទាប់ពីបំពេញបានតាមលក្ខខណ្ឌទាមទារមួយចំនួនតែប៉ុណ្ណោះ ដូចជាការចុះបញ្ជីបានត្រឹមត្រូវនៃសហជីព ដូចការដែលវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀតមិនបានទទួលជោគជ័យ (ដូចជាការចរចា ការផ្សះផ្សា ឬការដោះស្រាយដោយអាជ្ញាកណ្តាល ជាដើម) ការបញ្ចប់រយៈពេលរង់ចាំ ៦០ ថ្ងៃ បន្ទាប់ពីមានលេចឡើងនូវជម្លោះ ការបោះឆ្នោតដោយសម្ងាត់របស់សមាជិកសហជីព និងការជូនដំណឹងជាមុនរយៈពេលប្រាំពីរថ្ងៃទៅកាន់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ អ្នកធ្វើកូដកម្មត្រូវមានទោសព្រហ្មទណ្ឌ បើពួកគេបិទផ្លូវ មាត់ច្រកចូល ឬប្រព្រឹត្តអ្វីផ្សេងទៀត ដែលអាជ្ញាធរមូលដ្ឋានចាត់ទុកថាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ នៅពេលសហជីពបានបោះឆ្នោតសម្រេចចិត្តអោយធ្វើកូដកម្មហើយ ដែលទាមទារអោយមានការយល់ព្រមដោយសម្លេងភាគច្រើននៃសមាជិកសហជីព ដោយមាន៥០% នៃសមាជិកសហជីពបានគ្រប់កូរ៉ុម តុលាការអាចចេញសេចក្តីសម្រេចប្រឆាំងនឹងការធ្វើកូដកម្ម ហើយតម្រូវអោយចាប់ផ្តើមឡើងវិញនូវការចរចាជាមួយនិយោជក។

ការពង្រឹងការអនុវត្តសិទ្ធិដោយរដ្ឋាភិបាល ក្នុងការចូលរួមក្នុងសមាគម ដោយរួមទាំងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសហជីព និងសេរីភាពក្នុងការធ្វើការចរចាអនុសញ្ញារួម មានលក្ខណៈមិនស៊ីសង្វាក់ទេ។ ទំនាក់ទំនងជិតស្និទ្ធក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និយោជក និងមេដឹកនាំសហជីព ពិសេសមេដឹកនាំនៃសហជីពដែលគាំទ្ររដ្ឋាភិបាល ដាក់កំហិតព្រំដែនលើឆន្ទៈរបស់រដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហានៃការរំលោភសិទ្ធិកម្មករ។ ទំនាក់ទំនងទាំងនេះធ្វើឲ្យរាំងស្ទះដល់ការងារឯករាជ្យរបស់សហជីព ពីព្រោះភាគច្រើននៃសហព័ន្ធសហជីពនៅក្នុងប្រទេសមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្ស

គ្រប់គ្រងប្រទេស ហើយមានតែភាគតិចទេដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សប្រឆាំង ឬធ្វើការដោយឯករាជ្យ។

ដំណោះស្រាយជម្លោះសមូហភាពមានភាពមិនស៊ីសង្វាក់គ្នា មួយភាគធំដោយសារមានខមួយចែងក្នុងច្បាប់សហជីព ដែលត្រូវបានបកស្រាយថា អនុញ្ញាតឲ្យសហជីពដែលមានសមាជិកច្រើនបំផុតធ្វើជាតំណាងសមាជិកនៅក្នុងជំលោះសមូហភាព។ បន្ទាប់ពីក្រសួងការងារចេញបទបញ្ជានៅខែកក្កដា ដោយបំភ្លឺថា សហជីពមានសមាជិកភាគតិចអាចធ្វើតំណាងសមាជិករបស់គេ នៅក្នុងនីតិវិធីដោះស្រាយជម្លោះសមូហភាព ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាស្ថាប័នឯករាជ្យមួយសម្រាប់ដោះស្រាយជម្លោះសមូហភាពរបស់កម្មករ បានដោះស្រាយជម្លោះសមូហភាពយ៉ាងតិចបំផុតមួយ ដែលត្រូវបានបញ្ជូនមកដោយសហជីពដែលគ្មានសមាជិកភាគច្រើន តែសកម្មជនមួយចំនួនបានត្អូញត្អែថា បទបញ្ជានោះដូចជាជ្រុលពេក ហើយនៅក្នុងការបកស្រាយច្បាប់ រហូតដល់ដើរផ្ទុយពីច្បាប់ទៅទៀត។ នៅមុនខែកក្កដា ចំនួនករណីដែលធ្លាក់ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឯករាជ្យបានធ្លាក់ចុះពីចំនួនជាង ៣០ ក្នុងមួយខែ នៅមុនច្បាប់សហជីពត្រូវបានអនុម័ត មកត្រឹម ២ ករណីក្នុងមួយខែនៅពេលក្រោយមក ដែលជាធ្វើឲ្យអ្នកសង្កេតការណ៍អន្តរជាតិសំដែងកង្វល់។

ជម្លោះនិមួយៗក្នុងការងារអាចយកទៅឲ្យតុលាការដោះស្រាយ ថ្វីបើប្រព័ន្ធតុលាការមានភាពលំអៀង និងគ្មានតម្លាភាពក្តី។ គ្មានតុលាការឯកទេសសម្រាប់ជម្លោះក្នុងការងារទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលស្នើសុំក្រសួងការងារឲ្យផ្តល់ការអនុញ្ញាតសម្រាប់ដំណើរការគម្រោងសាកល្បងមួយក្នុងការកាត់ក្តីជំលោះបុគ្គល ថ្វីបើសហជីពបានសំដែងកង្វល់ថា រដ្ឋាភិបាលចាត់ទុកជំលោះសមូហភាពថាជាជំលោះបុគ្គល ដើម្បីបន្ថយតម្លៃនៃសមាជិកភាពក្នុងសហជីព។

កម្មករបាននិយាយពីឧបសគ្គនានា នៅក្នុងការអនុវត្តសិទ្ធិរបស់គេក្នុងការចូលរួមក្នុងសមាគមដោយសេរី។ មានសេចក្តីរាយការណ៍ពីការរំខានរបស់រដ្ឋាភិបាល ទៅលើមេដឹកនាំកម្មករឯករាជ្យ ដោយរួមទាំងការចោទប្រកាន់តាមផ្លូវច្បាប់មិនសមរម្យ។ មេដឹកនាំកម្មករលេចធ្លោមួយចំនួន ដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ឬសហជីពឯករាជ្យបានរងការចោទប្រកាន់ ឬស្ថិតនៅក្រោមការឃ្លាំមើលពីតុលាការ។ សហភាពការងារកម្ពុជា (CLC) បានរាយការណ៍ថា មានមេដឹកនាំសហជីពយ៉ាងហោចណាស់ ២០ នាក់ ប្រឈមនឹងការចោទប្រកាន់ព្រហ្មទណ្ឌ។

នៅខែកក្កដា តុលាការក្រុងភ្នំពេញបានទម្លាក់ចោលបទចោទប្រកាន់ «រំលោភសេចក្តីទុកចិត្ត» ប្រឆាំងនឹងសកម្មជនការងារដ៏លេចធ្លោម្នាក់លោក មឿន តុលា។ អ្នកសង្កេតការណ៍ឯករាជ្យជឿថា ការចោទនោះមានលក្ខណៈនយោបាយ ដែលធ្វើអោយគាត់ត្រូវប្រឈមនឹងការពិន័យយ៉ាងច្រើន និងការជាប់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ តុលាការបានទម្លាក់ចោលករណីនេះបន្ទាប់ពីមានការស្រែកតវ៉ាជាអន្តរជាតិ។

មានសេចក្តីរាយការណ៍ថា មានជាបន្តនូវទម្រង់ដទៃទៀតនៃការយាយី។ ឧទាហរណ៍ នគរបាលបានឆ្មក់ចូលទៅក្នុងការិយាល័យអង្គការការងារមួយ ដែលធ្វើការងារផ្នែកតស៊ូមតិជូនកម្មករ ចំនួន២ដង គិតតាំងពីខែកក្កដាមក ដោយតាមសេចក្តីរាយការណ៍មកថា ដើម្បីរកមើលឯកសារចុះបញ្ជី ឯកសារពន្ធ ទិដ្ឋាការបុគ្គលិកបរទេស និងភស្តុតាងនៃការជួលអគារ។ សហជីព និងអង្គការខ្លះ បាននិយាយថា មន្ត្រីរដ្ឋាភិបាលបានគាបសង្កត ឲ្យម្ចាស់ផ្ទះឈប់ជួលផ្ទះឲ្យពួកគេ។ សហជីពមួយចំនួនបាននិយាយពីការយាយី និងការគំរាមកំហែងរបស់មន្ត្រីអាជ្ញាធរមូលដ្ឋាន ក្នុងពេលពួកគេរៀបចំការប្រជុំឬសិក្ខាសាលាធម្មតា ពិសេសក្នុងរយៈពេលមុនបោះឆ្នោតខែកក្កដា។

តាមសេចក្តីរាយការណ៍មកថា និយោជកខ្លះមិនព្រមចុះហត្ថលេខាទទួលស្គាល់សហជីពជាផ្លូវការទេ ដោយគ្មាននរណាធ្វើអ្វីពួកគាត់ ឬមិនព្រមបន្តកុងត្រារយៈពេលខ្លីដល់កម្មករដែលបានចូលរួមនៅក្នុងសហជីព (ប្រហែល ៨០% នៃកម្មករនៅក្នុងវិស័យកម្មន្តសាលផ្លូវការធ្វើការតាមកុងត្រារយៈពេលខ្លី)។ និយោជក និងមន្ត្រីអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ មិនព្រមផ្តល់ឯកសារចាំបាច់សម្រាប់ចុះបញ្ជិកាសហជីពទេ។ សកម្មជនការងារបាននិយាយថា ធនាគារជាច្រើនមិនបើកគណនីជូនសហជីពដែលមិនទាន់ចុះបញ្ជីទេ ថ្វីបើតាមច្បាប់ សហជីពមិនអាចចុះបញ្ជីបានទេរហូតទាល់តែគេបានផ្តល់ព័ត៍មានលម្អិតស្តីពីធនាគារសិន។ អាជ្ញាធរការងារថ្នាក់ខេត្ត តាមសេចក្តីរាយការណ៍មក បានទុកចោលដោយគ្មានកំណត់ថ្ងៃនូវពាក្យសុំចុះបញ្ជិកា ដោយសួររកឯកសារបន្ថែម ឬឲ្យដាក់ពាក្យមកសាជាថ្មី ដោយសារមានកំហុសបន្តិចបន្តួច នៅក្នុងរយៈពេលដាក់ពាក្យម្តងៗ ដែលកំណត់ត្រូវមានរយៈពេល ៣០ ថ្ងៃ។ តែមានភស្តុតាងបង្ហាញថា ការធ្វើដូច្នេះមានការថយចុះនៅត្រឹមពាក់កណ្តាលឆ្នាំ ពិសេសសម្រាប់សហជីពក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង។ ផ្ទុយពីនេះ សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) បានចុះបញ្ជីដោយជោគជ័យ នៅខែសីហា នៅក្នុងការខិតខំជាលើកទី ៥ របស់គេ ក្រោយការដាក់ពាក្យសុំលើកដំបូងនៅខែមករា។ ដោយគិតមកត្រឹមខែវិច្ឆិកា មានតែសមាជិកសហជីពមូលដ្ឋានចំនួន ១២ ប៉ុណ្ណោះក្នុងចំណោមសមាជិករបស់សហព័ន្ធនេះចំនួន ៤២ ដែលអាចចុះបញ្ជីបាន។

អត្រាចូលជាសមាជិកក្នុងសហជីពមានភាពខុសគ្នា រវាងវិស័យផ្សេងៗនៃសេដ្ឋកិច្ច។ នៅក្នុងឧស្សាហកម្មបដិសណ្ឋារកិច្ច អត្រាមានជិត ២០%។ នៅក្នុងវិស័យកាត់ដេរស្បែកជើង និងសំលៀកបំពាក់ផ្លូវការ ទោះបីមានសហជីពច្រើនក្តី តែអត្រាអ្នកចូលជាសមាជិកមានតែពី ២០ ទៅ ៣០ ភាគរយតែប៉ុណ្ណោះ។ សហជីពទាំងនេះជាច្រើនតំណាងផលប្រយោជន៍នៃថៅកែរោងចក្រ និងគណបក្ស CPP ជាជាងផលប្រយោជន៍របស់កម្មករ។ នៅឆ្នាំ ២០១៧ ការសិក្សាមួយរបស់សហព័ន្ធ BWTUC បានបង្ហាញអោយឃើញថា មានតែ ៩%នៃអ្នកធ្វើការផ្នែកសំណង់ចំនួន ១០១០ នាក់នៅទូទាំងការដ្ឋាននៅភ្នំពេញ គឺជាសមាជិកសហជីព ឬសមាជិកសមាគម។

មានរបាយការណ៍នានាគួរអោយជឿទុកចិត្តថា កម្មករត្រូវបានបណ្តេញចេញពីការងារដោយសារហេតុផលមិនសមរម្យ បន្ទាប់ពីបានរៀបចំ ឬចូលរួមក្នុងកូដកម្ម។ ទោះបីជាកូដកម្មភាគច្រើនខុសច្បាប់ក៏ដោយ ក៏ការចូលរួមនៅក្នុងកូដកម្មខុសច្បាប់មិនអាចជាហេតុផល ដែលអាចទទួលយកបានដោយស្របច្បាប់សម្រាប់ការបណ្តេញកម្មករពីការងារឡើយ ។ ក្នុងករណីមួយចំនួន និយោជកមិនបន្តកុងត្រាយៈពេលខ្លីសម្រាប់សមាជិកសហជីពដែលសកម្មទេ ហើយក្នុងករណីខ្លះទៀត និយោជកបានគាបសង្កត់កូដករ ឬបុគ្គលិកសហជីពទទួលយកសំណង ហើយលាលែងពីការងាររបស់ខ្លួន ។ ចលនាសហជីពជាទូទៅបានមើលឃើញថា រដ្ឋាភិបាលមិនបានដោះស្រាយអ្វីអោយមានប្រសិទ្ធភាពទេ ចំពោះការបណ្តេញចេញបែបនេះ។

អង្គការពលកម្មអន្តរជាតិ (ILO) បានកត់សម្គាល់ពីការរើសអើងទៅលើសហជីពដោយនិយោជកតាមរយៈការជ្រៀតជ្រែកនិងការបណ្តេញសមាជិកនៃសហជីពឯករាជ្យ ព្រមទាំងតាមរយៈការបង្កើតសហជីពដែលគាំទ្រដោយនិយោជក។ ទោះបីជាច្បាប់ផ្តល់ការការពារដល់មេដឹកនាំសហជីពក្តី តែមានរោងចក្រជាច្រើនបានបញ្ចប់ការងាររបស់មន្ត្រីសហជីពប្រកបដោយជោគជ័យ មុនពេលសហជីពអាចទទួលបានការចុះបញ្ជីជាផ្លូវការ។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៃអង្គការ ILO បានរកឃើញកង្វល់ជាបន្តលើលទ្ធភាពរបស់កម្មករ ក្នុងការបង្កើត និងចូលរួមក្នុងសហជីពដោយសេរី ការជ្រៀតជ្រែករបស់ថៅកែនៅក្នុងសហជីព និងការគ្រប់គ្រងរបស់ថៅកែលើសហជីព។ ទំហំ

គ្របដណ្តប់របស់ BFC មានកម្រិតត្រឹមវិស័យនាំចេញទេ ដូច្នេះកម្រិតពិតប្រាកដនៃការយាយីលើសហជីពប្រហែលមានច្រើនជាងនេះឆ្ងាយ ពិសេសនៅតាមរោងចក្រដែលគ្មានការចុះបញ្ជិកា។

**ខ. ការហាមការងារដោយបង្ខំ ឬដោយការតំរូវ**

ច្បាប់ហាមប្រាមគ្រប់ទម្រង់ទាំងអស់នៃការងារដោយបង្ខំ ឬដោយការតម្រូវ។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះអោយមានប្រសិទ្ធភាពទេ។ មន្ត្រីនានាបាននិយាយពីការលំបាកនៅក្នុងការបញ្ជាក់ពីស្ថានភាពការងារ និងប្រាក់ខែ នៅក្នុងវិស័យក្រៅផ្លូវការក្នុងផ្នែកនៃសាទ កសិកម្ម សំណង់ និងការងារបំរើតាមផ្ទះ។ ការផាកពិន័យដែលកំណត់ដោយច្បាប់ ចំពោះការបង្ខំអោយធ្វើពលកម្មគឺមានភាពតឹងតែង ដោយរួមមានទាំងការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់។

ថ្វីបើរដ្ឋាភិបាលប្រឹងប្រែងក្នុងការលើកឡើងពីបញ្ហានៃការងារដោយបង្ខំ នៅក្នុងប្រទេសក្តី តែប្រសិទ្ធភាពនៃការខិតខំទាំងនេះនៅមិនច្បាស់។ លើសពីនេះទៀត មានភស្តុតាងខ្លះដែលបង្ហាញថានិយោជកបានធ្វើការជាមួយសមត្ថកិច្ចមូលដ្ឋាន ដើម្បីធ្វើឲ្យកម្មករជាប់ក្នុងទាសភាពបំណុលពលកម្មដែលមានដូចជានៅក្នុងឧស្សាហកម្មឡឥដ្ឋ។ ឧទាហរណ៍ របាយការណ៍ឆ្នាំ២០១៦ របស់អង្គការសិទ្ធិមនុស្សក្នុងស្រុកលីកាដូ (LICADHO) បានបង្ហាញពីពលកម្មកុមារ និងពលកម្មទាសភាពបំណុល នៅតាមឡឥដ្ឋដោយរួមទាំងមានភស្តុតាងនៃនិយោជកប្រើអាជ្ញាធរមូលដ្ឋាន ដើម្បីទុកកម្មករឲ្យស្ថិតនៅក្នុងពលកម្មទាសភាពបំណុល។ ថ្វីបើពីដំបូង រដ្ឋាភិបាលបានបដិសេធរបាយការណ៍ ហើយគំរាមកាត់ទោសពីបទបរិហារកេរ្តិ៍ ប្រសិនបើរបាយការណ៍ត្រូវបានរកឃើញថាមិនពិតក្តី តែនៅខែឧសភា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) បានរាយការណ៍ថា ខ្លួនបានបិទរោងចក្រផលិតឥដ្ឋចំនួន ៣ ពីបទរំលោភលើពលកម្មកុមារ ហើយកំពុងធ្វើការស៊ើបអង្កេតលើរោងចក្រចំនួន ១០០ ថែមទៀត។

បំណុលដែលជំពាក់ភាគីទី ៣ នៅតែជាបញ្ហាសំខាន់មួយនៅក្នុងការជម្រុញឲ្យមានពលកម្មដោយបង្ខំ។ បើយោងតាមការរកឃើញនៃការសិក្សាអង្កេតរបស់ BWTUC ដែលត្រូវបានធ្វើនៅក្នុងឆ្នាំ ២០១៧ មាន ៤៨% នៃកម្មករសំណង់ចំនួន ១០១០ នាក់ នៅភ្នំពេញជំពាក់បំណុលគេ ៧៥% នៃពួកគេជំពាក់សហគ្រាសមីក្រូហិរញ្ញវត្ថុ ឬធនាគារ ហើយមាន ២៥% ជំពាក់លុយសមាជិកគ្រួសារ។

ការបង្ខំឲ្យធ្វើការ ដែលតាមធម្មតា ទាក់ទងនឹងការងារលើសម៉ោង កើតមាននៅតាមរោងចក្រសំលៀកបំពាក់ និងរោងចក្រវាយនភណ្ឌសម្រាប់នាំចេញចំនួន ៦ក្នុងចំណោមរោងចក្រចំនួន ៣៩៥ អត្រា គឺមានប្រហាក់ប្រហែលនឹងឆ្នាំ ២០១៧ ។ កម្មករត្រូវមានការយល់ព្រមពីប្រធានជាបរទេស មុនពេលគេអាចចេញពីរោងចក្របាន ហើយកម្មករត្អូញត្អែរថា គេខ្លាចគេបញ្ឈប់ពីការងារ បើសិនជាគេមិនព្រមធ្វើការលើសម៉ោង។

កុមារក៏ប្រឈមនឹងការបង្ខំអោយធ្វើពលកម្មដែរ (សូមមើលផ្នែក ៧.គ)។

សូមមើលផងដែរនូវរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញ ដូរមនុស្ស* តាមអាស័យដ្ឋាន www.state.gov/j/tip/rls/tiprpt/ ។

**គ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរមាដែលអាចធ្វើការបាន**

ច្បាប់បានកំណត់ថា អាយុ១៥ឆ្នាំ គឺជាអាយុអប្បបរមា សម្រាប់បំពេញការងារ និង អាយុ១៨ ឆ្នាំជាអាយុអប្បបរិមា សម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់ ។ ច្បាប់អនុញ្ញាតកុមារ អាយុចន្លោះពី១២ ទៅ ១៥ឆ្នាំ ធ្វើ «ការងារស្រាល» ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សារបស់គេ ។ បទបញ្ញាសម្រាប់អនុវត្តមាននិយាយច្រើនពីសកម្មភាព ដែលត្រូវបានចាត់ទុកថាជា «ការងារធ្ងន់» ។ សកម្មភាពទាំងនេះរួមមានកសិកម្ម ការធ្វើឥដ្ឋ នេសាទ ថ្នាំជក់ និងផលិតកម្មដំឡូង។ ច្បាប់កំណត់ព្រំដែនកុមារដែលស្ថិតក្នុងអាយុពី ១២ ដល់ ១៥ ឆ្នាំ ធ្វើការយ៉ាងច្រើនត្រឹម ៤ ម៉ោងនៅថ្ងៃរៀន និង យ៉ាងច្រើនត្រឹម ៧ ម៉ោងនៅថ្ងៃអត់រៀន ហើយហាមប្រាមការធ្វើការពីម៉ោង ៨ យប់ដល់ម៉ោង ៦ ព្រឹក។ ការការពារចំពោះអាយុអប្បបរមាគ្មានទេសំរាប់កុមារធ្វើការបម្រើតាមផ្ទះ។

ច្បាប់ការងារចែងពីការពិន័យជាប្រាក់ចំនួនពី ៣១ ដងទៅ ៦០ ដងនៃប្រាក់ឈ្នួលប្រចាំថ្ងៃបច្ចុប្បន្ន ចំពោះជនដែលរំលោភលើបញ្ញាតិរបស់ជាតិស្តីពីពលកម្មកុមារ។ នៅឆ្នាំ ២០១៧ នាយកដ្ឋានពលកម្មកុមារ ដែលស្ថិតនៅក្រោមក្រសួងការងារ បានទទួលថវិកាពីរដ្ឋាភិបាលជាលើកដំបូង។ រដ្ឋាភិបាលបានផ្តល់ប្រាក់ចំនួន ៤០ លានរៀល (១០ ០០០ ដុល្លា) សម្រាប់ប្រតិបត្តិការពង្រឹងច្បាប់ស្តីពីពលកម្មកុមារ និងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ថ្វីបើគ្មានអ្នកពាក់ព័ន្ធណាម្នាក់ ដែលមានការងារទាក់ទងនឹងការប្រឆាំងពលកម្មកុមារ ជឿថា ចំនួននេះគ្រប់គ្រាន់នោះទេ។ នាយកដ្ឋាននេះ មានអ្នកធ្វើអធិការកិច្ចចំនួន ៣៣ រូប នៅភ្នំពេញ និងអធិការថ្នាក់ការងារកុមារម្នាក់ នៅតាមខេត្តនិមួយៗក្នុងចំណោមខេត្តក្រុងទាំង ២៥។ អធិការកិច្ចលើពលកម្មកុមារផ្តុំនៅទីក្រុងភ្នំពេញ និងនៅតាមរោងចក្រក្នុងវិស័យផ្លូវការនៅតាមខេត្ត ដែលផលិតទំនិញសម្រាប់នាំចេញ ជាជាងតំបន់ជនបទ ដែលមានចំនួនកុមារធ្វើពលកម្មលើសលុប។ នាយកដ្ឋានបានចាប់ផ្តើមធ្វើអធិការកិច្ចដោយមិនប្រកាសប្រាប់មុនតាមបណ្តឹង និងអធិការកិច្ចតាមដានបន្ត នៅក្នុងឆ្នាំនៃរបាយការណ៍នេះ តែមិនបានញឹកញាប់ទេ។ នៅឆ្នាំ ២០១៧ រដ្ឋាភិបាលដាក់ការពិន័យពីបទរំលោភលើពលកម្មកុមារចំនួន ៤២ ករណី។ ចំនួននេះគឺទាបជាងឆ្ងាយណាស់ទៅនឹងពលកម្មកុមារដែលគេនិយាយថា មានច្រើននៅក្នុងប្រទេស កម្ពុជា។

ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ធ្វើឲ្យអាជ្ញាធរមូលដ្ឋានខ្វះសមត្ថភាព នៅក្នុងការពង្រឹងការអនុវត្តបទបញ្ញាទាំងនេះ ពិសេសនៅតាមតំបន់ជនបទ និងនៅក្នុងវិស័យដែលមានការប្រឈមខ្លាំង ហើយគេមានការសង្ស័យទៅលើភាពពេញលេញនៃការធ្វើអធិការកិច្ច។ ឧទាហរណ៍ អធិការរបស់ក្រសួងបានចុះទៅតាមកន្លែងផលិតឥដ្ឋនានា នៅឆ្នាំ ២០១៧ តែគ្មានឃើញបទរំលោភលើពលកម្មកុមារទេ ទោះបីជាមានការនិយាយច្រើនមកថា មានកុមារធ្វើការនៅតាមកន្លែងផលិតឥដ្ឋ ក្បឿង។ បន្ថែមពីលើនេះទៀត ទណ្ឌកម្មចំពោះការរំលោភនៅក្នុងការងារ រួមទាំងបទរំលោភទាក់ទងនឹងពលកម្មកុមារ កម្រត្រូវបានដាក់ ស្របទៅតាមច្បាប់ណាស់។

មានពលកម្មកុមារក្នុងទម្រង់អាក្រក់បំផុត ដូចជានៅក្នុងការងារកសិកម្ម កន្លែងធ្វើឥដ្ឋក្បឿង និងការជួញដូរផ្លូវភេទ (សូមមើលផ្នែក ៦ ស្តីពីកុមារ) ។ ការមិនសូវទទួលបានការសិក្សាជាមូលដ្ឋាន និងការគ្មានកំណត់ថាចាំបាច់ត្រូវអោយរៀនដល់ត្រឹមណានោះ រួមចំណែកធ្វើឲ្យកុមារងាយរងការកេងប្រវ័ញ្ច។ កុមារមកពីគ្រួសារក្រីក្រងាយរងគ្រោះ ដោយសារគ្រួសារអ្នកមានខ្លះ តាមសេចក្តីរាយការណ៍មកថា ធ្វើជាចិត្តល្អហើយជួលកុមារបម្រើការងារក្នុងផ្ទះ តែបែរជារំលោភធ្វើបាប និងកេងប្រវ័ញ្ចទៅវិញ។ កុមារក៏រងផងដែរនូវការបង្ខំឲ្យដើរសុំទាន។

ពលកម្មកុមារនៅតាមរោងចក្រស្បែកជើង និងសំលៀកបំពាក់សម្រាប់ការនាំចេញមានការថយចុះច្រើន នៅក្នុងពេលប៉ុន្មានឆ្នាំនេះ។ អ្នកវិភាគខ្លះគិតថា ការនេះបណ្តាលមកពីការគាបសង្កត់នៃ

កម្មវិធីតម្រូវឲ្យមានការកែលម្អចាំបាច់របស់គម្រោង BFC ។ តាំងពីឆ្នាំ ២០១៥ មក BFC បានរកឃើញកុមារធ្វើពលកម្មចំនួនមិនដល់ ២០ នាក់ទេ ក្នុងមួយឆ្នាំ ក្នុងចំណោមរោងចក្រប្រមាណ ៨០០។ នៅក្នុងរបាយការណ៍សរុបចុងក្រោយរបស់ខ្លួន សំរាប់រយៈពេលពីថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ BFC បានរកឃើញករណីចំនួន ១០ ដែលក្នុងនោះ កុមារអាយុក្រោម ១៥ ធ្វើការនៅតាមរោងចក្រ។

សូមចូលមើលនូវការរកឃើញស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមាររបស់ ក្រសួងការងារសហរដ្ឋអាមេរិក តាមគេហទំព័រ WWW.dol.gov/ilab/reports/child-labor/findings/។

**ឃ. ការរើសអើងទាក់ទងនឹងការងារ**

ច្បាប់ហាមការរើសអើងក្នុងការងារ ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព សាសនានាគំនិតនយោបាយ កំណើត ប្រភពដើមក្នុងសង្គម ឬសមាជិកភាពក្នុងសហជីពទេ។ ច្បាប់ពីរដាច់ដោយឡែកពីគ្នាហាមយ៉ាងច្បាស់នូវការរើសអើង ដោយសារតែការមានមេរោគអេដស៍។ ច្បាប់មិនហាមច្បាស់នូវការរើសអើងដោយផ្អែកលើចំណង់ផ្លូវភេទ អត្តសញ្ញាណយេនឌ័រ អាយុ ភាសា ឬជំងឺឆ្លងទេ។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋទាំងពីរភេទទទួលបានប្រាក់បៀវត្សរ៍ស្មើគ្នា ចំពោះការងារស្មើគ្នា។

ជាទូទៅ រដ្ឋាភិបាលមិនពង្រឹងការគោរពចំពោះច្បាប់ទាំងនេះទេ។ តាមច្បាប់ ទណ្ឌកម្មចំពោះការរើសអើងក្នុងការងាររួមមានការពិន័យជាប្រាក់ សំណងប៉ះប៉ូវរដ្ឋប្បវេណី និងរដ្ឋបាល។ ប្រាក់ពិន័យចំពោះការងាររើសអើងក្នុងការងារមានពី ២,៥ ទៅ ៣,៦ លានរៀល (៦២៥ដុល្លា ទៅ ៩០០ ដុល្លា)។

មនុស្សប្រុសស្រីបន្តប្រឈមនឹងការរើសអើងក្នុងការ នៅក្នុងឧស្សាហកម្មនានា។ បើយោងតាមការសិក្សាអង្កេតមួយរបស់ BWTUC ការងារប្រចាំថ្ងៃសំរាប់កម្មករសំណង់ប្រុសមានប្រាក់ឈ្នួល ២០,២% ច្រើនជាងប្រាក់ឈ្នួលសំរាប់ការងារដូចគ្នារបស់កម្មការិនី។ កម្មវិធី BFC បាននិយាយថា នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ថៅកែរោងចក្ររើសអើងយ៉ាងខ្លាំងទៅលើបុរសក្នុងការរើងជ្រើសរើសចូលធ្វើការ និងការផ្តល់ប្រាក់បំណាច់ ដោយគេយល់ថា បុរសច្រើនមានបញ្ហាទាក់ទងនឹងអាកប្បកិរិយាដោយជាទូទៅ ការធ្វើដូច្នេះគ្មានរងផលវិបាកផ្លូវច្បាប់ឡើយ។ BFC បាននិយាយថា ៧% នៃរោងចក្រដែលមានអាជ្ញាប័ណ្ណសំរាប់ការនាំចេញ មានការរើសអើងផ្អែកជេនឌ័រ ចំណែក ២% ត្រូវបានរាយការណ៍មកថាបញ្ចប់ការងាររបស់ស្ត្រីមានផ្ទៃពោះ ឬបង្ខំអោយពួកគេលាលែងពីការងារ។

នៅក្នុងរបាយការណ៍ខែមករា BFC បានរកឃើញថា រោងចក្រចំនួន ៣៧ (៨% នៃរោងចក្រទាំងអស់នៅក្នុងប្រទេស) មានទម្លាប់រើសអើងតិចតួច រោងចក្រចំនួន ១០ មិនបានបណ្តេញចេញស្ត្រីមានផ្ទៃពោះទេ ហើយរោងចក្រចំនួន ៨ មិនបានរើសអើងទៅលើកម្មករ ដោយសារការចូលជាសមាជិកសហជីពទេ។

ការយាយីលើស្ត្រីមានច្រើន។ គម្រោងស្រាវជ្រាវធំមួយ ដែលធ្វើដោយអង្គការ Care International បានរកឃើញថា ចំនួន ១ ភាគ ៣ នៃនារីនៅក្នុងឧស្សាហកម្មកាត់ដេរបានទទួលរងនូវការយាយីផ្លូវភេទនៅក្នុងរយៈពេល ១២ ខែមុន។ បើយោងតាមរបាយការណ៍របស់ BFC កាលពីខែមិនា កម្មករចំនួន ៣៨% ដែលបានអង្កេតទៅលើ មានអារម្មណ៍មិនល្អ «ជាញឹកញាប់» ឬ «នៅពេលខ្លះ» ដោយសារអាកប្បកិរិយានៅក្នុងរោងចក្រ ហើយ ៤០% នៃកម្មករមិនជឿថា មានប្រព័ន្ធច្បាស់លាស់ និងត្រឹមត្រូវ សម្រាប់ឲ្យគេរាយការណ៍ពីការយាយីផ្លូវភេទ នៅក្នុងរោងចក្ររបស់គេទេ។

## ង.លក្ខខណ្ឌការងារដែលអាចទទួលយកបាន

នៅមុនខែមិថុនា ច្បាប់មិនបានកំណត់បៀវត្សរ៍អប្បបរមាសំរាប់វិស័យណាមួយទេ លើកលែងតែវិស័យកាត់ដេរសំលៀកបំពាក់។ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលបានអនុម័តនៅខែមិថុនា ពង្រីកប្រាក់ឈ្នួលអប្បបរមាអោយគ្របដណ្តប់វិស័យថ្មីៗទៀត ឬគ្របដណ្តប់វិស័យសេដ្ឋកិច្ចផ្លូវការទាំងមូល តែគ្មានការទាមទារឲ្យកំណត់រង្វង់ពេលវេលាឲ្យច្បាប់ធ្វើដូច្នេះទេ។ បញ្ញត្តិថ្មីមិនបានចូលជាធរមានទេ នៅក្នុង នៅក្នុងឆ្នាំនៃរបាយការណ៍នេះ។ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក៏បានបង្កើតផងដែរនូវក្រុមប្រឹក្សាជាតិស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលមានតំណាងមកពីរដ្ឋាភិបាល សហជីព និងអង្គការរបស់និយោជកដើម្បីធ្វើការស្រាវជ្រាវ និងផ្តល់អនុសាសន៍ស្តីពីប្រាក់ឈ្នួលអប្បបរមា។ គិតមកត្រឹមខែវិច្ឆិកា រដ្ឋាភិបាលមិនបានបំភ្លឺពីវិធីដែលសមាជិកភាពនៅក្នុងស្ថាប័នប្រាក់ឈ្នួលត្រីភាគីថ្មីនេះត្រូវបានជ្រើសរើសនោះទេ។ សមាគមអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអង្គការសង្គមស៊ីវិលបានរិះគន់ច្បាប់នេះថា មិនបានគ្រប់ដណ្តប់លើអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅផ្លូវការទេ។ តែប្រាក់ឈ្នួលអប្បបរមាឆ្នាំ ២០១៩ ត្រូវបានកំណត់កាលពីខែតុលា នៅក្រោមប្រព័ន្ធក្រុមប្រឹក្សាផ្តល់ប្រឹក្សាការងារ ដែលកំណត់ប្រាក់ឈ្នួលតែសម្រាប់វិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើងទេ។ ប្រាក់ឈ្នួលអប្បបរមា គឺលើសពីការប៉ាន់ប្រមាណជាផ្លូវការសម្រាប់កម្រិតប្រាក់ចំណូលនៃភាពក្រីក្រ។

ច្បាប់មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍តាមបទដ្ឋានស្របច្បាប់ចំនួន ៤៨ម៉ោង មិនអោយលើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់កំណត់អត្រា ១៣០ ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃ សម្រាប់វេនការងារនៅពេលយប់ និង ១៥០ ភាគរយសម្រាប់ការងារបន្ថែមម៉ោង ដែលត្រូវកើនឡើងដល់ ២០០ ភាគរយ ប្រសិនបើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាក ។ និយោជិកត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងយ៉ាងច្រើន ២ ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់ហាមការធ្វើការលើសម៉ោងជ្រុល ចែងថា ការធ្វើការលើសម៉ោងទាំងអស់ត្រូវតែទៅតាមការស្ម័គ្រចិត្ត ហើយចែងពីការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។ អ្នកធ្វើការនៅផ្នែកដឹកជញ្ជូនតាមទឹក និងអាកាសមិនទទួលបានប្រាក់ឧបត្ថម្ភផ្នែកសង្គម និងប្រាក់ចូលនិវត្តន៍ទេហើយត្រូវបានលើកលែងពីការកំណត់ព្រំដែនម៉ោងការងារ ដែលត្រូវបានចែងដោយច្បាប់។

នៅខែមិថុនា បន្ទាប់ពីមានរោងចក្រយ៉ាងហោចណាស់ចំនួន ៩ បានបិទទ្វារភ្លាមៗ នៅឆមាសទី ១ ដោយមិនបានបង់ប្រាក់ជាង ៨៨ ពាន់លានរៀល (២២ លានដុល្លា) ជាប្រាក់ឈ្នួលដែលត្រូវបង់ ឬប្រាក់បំណាច់ដែលត្រូវបង់ជូនកម្មករ រដ្ឋាភិបាលបានធ្វើវិសោធនកម្មលើច្បាប់ ដើម្បីលុបបំបាត់ប្រាក់បំណាច់សំរាប់និយោជិត ដែលធ្វើការតាមកុងត្រារយៈពេលខ្លី។ ជាជំនួសវិញ ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្មនេះតម្រូវអោយបង់ប្រាក់ស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការចំនួន១៥ ថ្ងៃ ដែលត្រូវបង់រាល់ ៦ ខែម្តង ទៅអោយនិយោជិតទាំងអស់ ដែលធ្វើការតាមកុងត្រាមិនកំណត់រយៈ ពេល។

សុខភាពនៅកន្លែងធ្វើការ និងបទដ្ឋានសុវត្ថិភាពត្រូវតែគ្រប់គ្រាន់ដើម្បីផ្តល់សុខុមាលភាព ដល់កម្មករ ។ អធិការការងារវាយតម្លៃប្រាក់ពិន័យ ដោយយោងទៅតាមរូបមន្តស្មុគស្មាញ ផ្អែកលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃកំហុស ព្រមជាមួយនឹងចំនួនកម្មករដែលទទួលរង។ អធិការរបស់ក្រសួងការងារមានអំណាចវាយតម្លៃប្រាក់ពិន័យទាំងនេះ នៅនឹងកន្លែង ដោយមិនបាច់មានការសហការពីនគរបាលទេ តែគ្មានបទបញ្ញត្តិជាក់ច្បាស់ណាមួយសម្រាប់ការពារកម្មករ ដែលគេចវាំពីស្ថានភាពប៉ះពាល់ដល់សុខភាព ឬគ្មានសុវត្ថិភាពទេ។

ក្រសួងការងារ គឺជាអ្នកទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តច្បាប់ការងារ តែចំនួនអធិការ មានមិនគ្រប់សម្រាប់ធ្វើអធិការកិច្ចអោយបានពេញលេញ។ ការពិន័យកម្រត្រូវបានវាយតម្លៃណាស់ ហើយ មានមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាទេ។ រដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ថែមម៉ោង និងម៉ោងការងារឲ្យមានប្រសិទ្ធភាពទេ។ នៅក្រៅឧស្សាហកម្មកាត់ដេរ រដ្ឋាភិបាលកម្រពង្រឹង ការអនុវត្តលើបទបញ្ញាស្តីពីម៉ោងការងារណាស់។ រដ្ឋាភិបាលពង្រឹងការអនុវត្តលើបទដ្ឋាននានា ដោយ អន្លើដោយសារខ្លួន ខ្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងបរិក្ខារចាំបាច់ ហើយនិងកា មានអំពើពុករលួយ ។ មន្ត្រីរបស់ក្រសួងការងារ បានសារភាពពីភាពអសមត្ថភាព នៅក្នុងការធ្វើអធិការ កិច្ចពេញលេញលើម៉ោងការងារ ហើយពឹងទាំងស្រុងលើ BFC ឲ្យធ្វើការងារនេះ នៅតាមរោងចក្រដេរសំលៀកបំពាក់សំរាប់នាំចេញ។

កម្មករបានរាយការណ៍ថា ការងារលើសម៉ោងច្រើនហួសកម្រិត ហើយជួនកាលគេតម្រូវឲ្យធ្វើជា ចាំបាច់ទៀតផង ។ មានច្រើនគ្នាបានត្អូញត្អែរថា ថៅកែបង្ខំគេធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃ ថ្វីបើច្បាប់ កំណត់ត្រឹម ១០ ម៉ោងក្តី ដោយរួមទាំងម៉ោងលើសផង។ ជាញឹកញាប់ កម្មករប្រឈមនឹងការពិន័យជា ប្រាក់ ការបណ្តេញចេញ ឬការបាត់បង់ប្រាក់បន្ថែម ប្រសិនបើគេមិនព្រមធ្វើការថែមម៉ោង។ កម្មករ និង អង្គការពលកម្មនានាមានកង្វល់ផងដែរថា ការប្រើកុងត្រារយៈពេលខ្លី ពិសេសនៅក្នុងវិស័យកាត់ដេរ ដែលកំណើននៃផលិតភាពច្រើននៅទ្រឹងមិនឡើង អនុញ្ញាតឲ្យក្រុមហ៊ុនគេចផុតពីលក្ខខណ្ឌទាមទារខ្លះ តាមច្បាប់ និងលើប្រាក់បៀវត្សរ៍។ កុងត្រារយៈពេលខ្លីថែមទាំងអនុញ្ញាតឲ្យថៅកែមានសេរីភាពច្រើន ក្នុង ការបញ្ចប់ការងាររបស់អ្នករៀបចំបង្កើតសហជីព និងនារីមានផ្ទៃពោះ ដោយគ្រាន់តែមិនបន្តកុងត្រាអោយពួកគេ។ ច្បាប់កំណត់រយៈពេលកុងត្រាត្រឹមច្រើនបំផុត ២៤ ខែ។ ជាធម្មតា ថៅកែជួលកម្មករតាមកុងត្រារយៈពេលខ្លី ជារហូត ដែលច្រើនតែមានរយៈពេល ៣ ខែម្តង។ ក្រសួងការងារ បកស្រាយច្បាប់នេះថា អនុញ្ញាតឲ្យមានការជួលតាមកុងត្រាតៗគ្នាបែបនេះ ដរាបណាមានការឈប់ពីការងារក្នុងពេលណាមួយ នៅក្នុងអំឡុងពេលរាល់ ២៤ ខែ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការ ILO បានជំទាស់នឹងការបកស្រាយ ច្បាប់នេះ ដោយទទូចថា ក្រោយរយៈពេល ២៤ ខែ កម្មករត្រូវតែទទួលបានជាអចិន្ត្រៃយ៍នូវ «កុងត្រាដែល មានរយៈពេលមិនកំណត់» (សូមមើលផ្នែក ៧.ក)។

ក្នុងការស្ទង់មតិមួយ នាខែមេសា ឆ្នាំ ២០១៧ ធ្វើឡើងដោយ BWTUC បានប៉ាន់ប្រមាណថា មាន មនុស្សប្រមាណ ២០០ ០០០ នាក់ ធ្វើការនៅក្នុងឧស្សាហកម្មសំណង់។ មាន ៨៩% នៃអ្នកឆ្លើយចំនួន ១០១០ នាក់ គ្មានកុងត្រាការងារទេ ភាគច្រើនមិនដែលទទួលប្រាក់បន្ថែម ឬប្រាក់បើកផ្តាច់ឲ្យពេលឈប់ធ្វើការ ទេ ហើយមានតែ ៩% មានឈ្មោះនៅក្នុងរបបជាតិសន្តិសុខសង្គម (NSSF) ។ របួសក្នុងពេលធ្វើការងារ និង បញ្ហាសុខភាពកើតមានឡើងជាញឹកញាប់ ។ រោងចក្រកាត់ដេរធំៗ ភាគច្រើនដែលផលិតសម្រាប់ទីផ្សារ នៅប្រទេសអភិវឌ្ឍ បានបំពេញបានល្អគួរសមតាមបទដ្ឋានអនាម័យ និងសុវត្ថិភាពការងារ ដែលជា លក្ខខណ្ឌសម្រាប់ចុះកិច្ចសន្យាជាមួយអតិថិជនទិញនៃផលិតផលរបស់ខ្លួន ។ ស្ថានភាពការងារនៅតាម រោងចក្រខ្នាតតូចមួយចំនួន និងឧស្សាហកម្មតូចៗ មានលក្ខណៈទន់ខ្សោយ ហើយជារឿយៗ មិនបាន បំពេញតាមបទដ្ឋានអន្តរជាតិទេ ។ នាយកដ្ឋានសុវត្ថិភាពការងារ និងសុខភាព (OSH) បាននិយាយថា នៅក្នុងរយៈពេល ៦ ខែដំបូង មានកម្មករចំនួន ២៥៣៣ នាក់បានរងរបួសក្នុងការងារ ដោយចំនួននេះ មានលើសពីចំនួននៅក្នុងឆ្នាំ ២០១៧។ ក្នុងចំណោមអ្នករបួសទាំងនេះ មាន ៤៤៤ នាក់បានរបួស ដោយសារគ្រោះថ្នាក់ចរាចរណ៍ ដោយសារថៅកែច្រើនដឹកកម្មករកាត់ដេរទៅមកកន្លែងធ្វើការ តាមរថយន្តធំដែលបើកចំហ និងគ្មានសុវត្ថិភាព។

ការដួលសន្លប់ទាំងហ្វូងៗនៅតែជាបញ្ហាមួយនៅឡើយ។ NSSF បានរាយការណ៍ថា កម្មករចំនួន ១៣៥០ នាក់បានដួលសន្លប់នៅក្នុងរោងចក្រចំនួន ១៣ នៅក្នុងរយៈពេល ៦ ខែដំបូង។ ចំនួននេះកើន លើសពីចំនួន ៤១៥ នាក់ ដែលបានដួលសន្លប់នៅតាមរោងចក្រចំនួន ៨ នៅក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៧។ គ្មានសេចក្តីរាយការណ៍ពីរបួសធ្ងន់ដោយសារការសន្លប់ទេ។ អ្នកសង្កេតការណ៍បាននិយាយពីការ ធ្វើការលើសម៉ោងជ្រុល សុខភាពទ្រុឌទ្រោម ការដេកមិនគ្រប់ ខ្យល់ចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភ ត្រឹមត្រូវសម្រាប់កម្មករ ថ្នាំសម្លាប់សត្វចង្រៃត្រូវបានបាញ់នៅក្នុងវាលស្រែក្បែរខាង ហើយចំហាយជាតិ ពុលចេញមកពីសកម្មភាពផលិតកម្មក៏មានចំណែកធ្វើអោយកម្មករសន្លប់ច្រើនគ្នាផងដែរ។

BFC បានរាយការណ៍ថា ការគោរពតាមបទដ្ឋានរបស់នាយកដ្ឋានសុវត្ថិភាពការងារ និងសុខភាព នៅតែជាបញ្ហាប្រឈមមួយដែលកាន់តែមានច្រើនឡើង នៅក្នុងវិស័យនាំចេញសំលៀកបំពាក់ ដោយសារ នីតិវិធី និងគោលនយោបាយរបស់ក្រុមហ៊ុនមិនសមស្រប ហើយនិងការទទួលខុសត្រូវ និងតួនាទី គ្រប់គ្រងមិនត្រូវបានកំណត់ច្បាស់។ BFC បាននិយាយពីការមិនគោរពកាន់តែច្រើនឡើង នៅក្នុងគ្រប់ ចំណុចទាំងអស់ដែលកំណត់ដោយនាយកដ្ឋាន ដោយរួមមានការរងនឹងសារធាតុគីមីគ្រោះថ្នាក់ ការ រៀបចំត្រៀមចំពោះគ្រាអាសន្ន ប្រព័ន្ធគ្រប់គ្រង OSH កន្លែងផ្តល់សុខុមាលភាព បរិស្ថានសម្រាប់កម្មករ ការការពារកម្មករ និងការស្នាក់នៅរបស់កម្មករ៕